មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0018**

# ជួបសម្ភាសន៍ជាមួយ សុក ជឿន ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«យោធា»

## រស់នៅភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១០

## សម្ភាសន៍ដោយ សោម ប៊ុនថន

០១:១៦:៣០

៤៥ទំព័រ

ប៊ុនថន : ជំបូងខ្ញុំសូមអនុញ្ញាតសួរឈ្មោះអ្នកមីងណា? ចង់សួរអ្នកមីងឈ្មោះអីដែរ?

ជឿន : សុខ ជឿន។

ប៊ុនថន : មីងអាយុប៉ុន្មានហើយ?

ជឿន : ៥៦ហើយ ។

ប៊ុនថន : មីងស្រុកកំណើតនៅឯណាដែរ?

ជឿន : ខ្ញុំនៅខេត្តព្រះវិហារ ស្រុក ភូមិស្ដៅ ស្រុកគូលែន ខេត្តព្រះវិហារ ។

ប៊ុនថន : មីងមានបងប្អូនប៉ុន្មាននាក់មីង?

ជឿន : បងប្អូនខ្ញុំ៦នាក់ ។

ប៊ុនថន : អ្នកមីងកូនទីប៉ុន្មាន?

ជឿន : ខ្ញុំកូនទី៤ ។

ប៊ុនថន : ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ជឿន : ប្រុសបី ស្រីបី ។

ប៊ុនថន : ចុះឪពុកម្ដាយអ្នកមីង?

ជឿន : ឪពុកម្ដាយរបស់ខ្ញុំស្លាប់អស់ហើយ ។ ឪពុកខ្ញុំស្លាប់តាំងពីខ្ញុំអាយុ៩ឆ្នាំ ។

ប៊ុនថន : ស្លាប់តាំងពីក្មេង ចុះម្ដាយ?

ជឿន : ម្ដាយខ្ញុំទើបស្លាប់បានប្រាំឆ្នាំ ឆ្នាំនេះ ។ ខ្ញុំអត់ដែលដឹងដំណឹងទេ ដល់ទៅស្រុកបានដឹង ។

ប៊ុនថន : មីងទៅស្រុកលេងអ្ហី?

ជឿន : ចាស!

ប៊ុនថន : មីងទៅបានប៉ុន្មានដង?

ជឿន ៖ ទៅបានពីរដងហើយ ។

ប៊ុនថន ៖ តាំងពីបែកគ្នាមក?

ជឿន ៖ បែកគ្នា បែកតាំងពី៧២មក ។ ចេញពីផ្ទះមកតាំងពីអាយុ១៧ឆ្នាំ ។

ប៊ុនថន ៖ ឆ្នាំ៧២ហ្នឹងមក?

ជឿន ៖ ចាស!

ប៊ុនថន ៖ មីងមានបានចូលរៀនអីទេមីង?

ជឿន ៖ ពីក្មេងមករៀនបានត្រឹមថ្នាក់១២ ១២សម័យនោះ ទី១១-១២ចុះមកក្រោមណា ។

ប៊ុនថន ៖ បាទ!

ជឿន ៖ អូ! ថ្នាក់ទី១១ ។ ចាស! រៀនបានពីរឆ្នាំ ។

ប៊ុនថន ៖ ប៉ុន្តែអានអីបានទេអ្នកមីង?

ជឿន ៖ បាន សរសេរបានខ្លះ ប៉ុន្តែពីមុនគ្រាន់ ឥឡូវដូចចាស់ទៅ ឈឺច្រើនអីចឹងទៅ គិតក៏អត់ឃើញ សរសេរក៏អត់កើត ។ ពីមុនអានអី សរសេរបាន ឥឡូវធ្វើអត់កើត ។

ប៊ុនថន ៖ ប៉ុន្តែឥឡូវអានអីបាន?

ជឿន ៖ អានបានខ្លះ មើលបាន ។

ប៊ុនថន ៖ សរសេរនេះ ។

ជឿន ៖ សរសេរអត់សូវកើត ។

ប៊ុនថន ៖ ដូចរាងភ្លេចៗ ។

ជឿន ៖ ចាស! ភ្លេច ។

ប៊ុនថន ៖ អីចឹងកាលឆ្នាំ៧២ហ្នឹង មីងចូលបដិវត្តន៍ម៉ងអ្ហី?

ជឿន ៖ ចាស!

ប៊ុនថន ៖ ចូលហ្នឹងជ្រើសរើសចូល ឬមួយ?

ជឿន ៖ គេជ្រើសរើស ខ្ញុំស្ម័គ្រចិត្តៗខ្លួនឯងម៉ង ។

ប៊ុនថន ៖ ស្ម័គ្រចិត្តហ្នឹង ដូចថាម៉េចបានមីងស្ម័គ្រចិត្តចូល?

ជឿន ៖ ចុះកាលណោះគេឃោសនារំដោះសម្តេចឪអីចឹងណា ចូលមកតស៊ូរំដោះសម្តេចឪ ដូចថាលះបង់គ្រួសារចូលតស៊ូណា ។

ប៊ុនថន ៖ ចុះឪពុកម្តាយដឹងទេ?

ជឿន ៖ កាលណោះម្តាយខ្ញុំគាត់ដឹង ខ្ញុំចេញមក ។

ប៊ុនថន :	គាត់មានឃាត់អ្នកមីងអីទេ ។

ជឿន :	ម៉ែៗដូចមិនឃាត់កូនទេ ។ ចាស! អត់មានឃាត់ទេ ។

ប៊ុនថន :	អ្នកមីងគាត់តាមកូន?

ជឿន :	ចាស! តាមកូន ។

ប៊ុនថន :	ប៉ុន្តែអ្នកមីងចង់ចូលតែម្តង?

ជឿន :	ចង់ចូលដោយខ្លួនឯង ដូចថាមានអង្គការអីគេទៅឃោសនាអីចឹងទៅ ដូចថាចង់ នៅក្មេង អត់ដឹងអី ចេះតែចង់ចូល ។

ប៊ុនថន :	ចូលជាមួយគ្នាច្រើនទេអ្នកមីង?

ជឿន :	មក មួយស្រុកខ្ញុំហ្នឹងមកគ្នាតែបួននាក់ទេ ។

ប៊ុនថន :	ស្រុកគូលែនហ្នឹង?

ជឿន :	ចាស! ដូចថាមានអ្នកគេមកមុនៗអីចឹងទៅ មួយវគ្គទៅ មានគេរើសមួយវគ្គៗទៅ ។

ប៊ុនថន :	បាទ! មកចូលជាមួយហ្នឹងមកចូលនៅឯណាទៅ?

ជឿន :	ចូលបដិវត្តន៍ហ្នឹង ខ្ញុំចូលជាមួយហ្នឹងចេញមកពីខេត្តខ្ញុំហ្នឹង ចេញពីតំបន់ខ្ញុំមកហ្នឹងនៅមជ្ឈិម តែម្តង ។

ប៊ុនថន :	នៅមជ្ឈិម?

ជឿន :	ចាស!

ប៊ុនថន :	នៅមជ្ឈិមនៅកន្លែងណា?

ជឿន :	នៅខាងតាៗគាត់គ្រប់គ្រង ។

ប៊ុនថន :	នៅកន្លែងណាវិញមីង នៅព្រះវិហារ ឬនៅ?

ជឿន :	អត់ទេ ខ្ញុំមកនៅកំពង់ចាម ។ ចាស! ក្នុងព្រៃកំពង់ចាម ។

ប៊ុនថន :	ចេញពីឆ្នាំ៧២ហ្នឹង ចេញពីហ្នឹងទៅកំពង់ចាមតែម្តង?

ជឿន :	ចេញពីស្រុកឆ្នាំ៧២ហ្នឹងមក នៅកំពង់ចាម ក្នុងព្រៃដូចកន្លែងបម្រើវគ្គកន្លែងអីៗហ្នឹង ។

ប៊ុនថន :	នៅហ្នឹងមីងធ្វើអីដែរ?

ជឿន :	កាលហ្នឹងធ្វើយុទ្ធនារីធម្មតាសម្រាប់បម្រើដាំបាយ ដាំអី ។

ប៊ុនថន :	កន្លែងៗអីៗហ្នឹង គេហៅៗអីវិញ គេមានឈ្មោះគេទេ?

ជឿន :	អត់ ខ្ញុំនៅអត់បានយូរ នៅបានត្រឹមមួយខែអីចឹង ខ្ញុំចេញមកនៅខាងទន្លេសាបហ្នឹង ។

ប៊ុនថន :	ខាងអីវិញមីង?

ជឿន ៈ ខាងទន្លេសាបហ្នឹង ពួកខ្ញុំនៅខាងដឹកជញ្ជូន ។

ប៊ុនថន ៈ ដឹកជញ្ជូន?

ជឿន ៈ ចាស! កងដឹកជញ្ជូន ។

ប៊ុនថន ៈ ដឹកជញ្ជូនហ្នឹងអត់មានលេខ អត់មានអីទេ?

ជឿន ៈ អត់ ចេញមកពីមជ្ឈិមផ្ទាល់ ។

ប៊ុនថន ៈ នៅកំពង់ចាម មីងនៅស្រុកអីវិញមានចាំទេ?

ជឿន ៈ អត់ អត់ស្គាល់ស្រុកផង មិនដឹងស្រុកអីនៅក្នុងព្រៃ អត់ស្គាល់ស្រុកទេ ។

ប៊ុនថន ៈ ខាងអ៊ឹៗហ្នឹង ខាងណាគ្រប់គ្រង ។

ជឿន ៈ កាលបើកវគ្គហ្នឹង ខ្ញុំជួបអ៊ឹៗមាន អ៊ឹ នួន ជា គាត់បើកវគ្គបង្រៀន ជួបច្រើនគឺអ៊ឹ នួន ជា ។

ប៊ុនថន ៈ គាត់នៅខាង អ្នកមីងនៅខាងហ្នឹង?

ជឿន ៈ ចាស! នៅដាំបាយ ដាំអីសម្រាប់ពួកគណៈភាគ គណៈតំបន់អីចឹងទៅ ។

ប៊ុនថន ៈ នៅហើយបានចេញមកខាងទន្លេសាប?

ជឿន ៈ ចាស! ខ្ញុំមកនៅទន្លេសាបហ្នឹង ខ្ញុំមកនៅខាងកងដឹកជញ្ជូន ដឹកជញ្ជូនហ្នឹងមិនមែនកងដឹកជញ្ជូនពិតប្រាកដទេ ខ្ញុំមកដូចថាគ្រាន់តែជួយកងដឹកជញ្ជូនទន្លេសាបត្រៀមទៅណា ត្រៀមពួកគេយកគ្រាប់រំសេវអីចឹងទៅណា ។ ហើយខ្ញុំអត់បានដឹកជញ្ជូនអីគេទេ គ្រាន់តែថានៅកាត់ដេរ នៅខាងកាត់ដេរខោអាវៗឧបត្ថម្ភនៅក្នុងអគ្គភាព ។ អគ្គភាពហ្នឹងមិនដឹងគេហៅអីត្រង់ណាទេ លេខគេដូច ស-៧១ អីទេ ខ្ញុំចាំមិនបាន ។

ប៊ុនថន ៈ ស-៧១ ។

ជឿន ៈ ដូចចាំមិនបានទេ បើខាងកាណូត គេហៅពួកខ្ញុំដឹកជញ្ជូនជើងទឹក ។

ប៊ុនថន ៈ បាទ! អីចឹងមីងនៅហ្នឹងយូរទេមីង នៅខាងដឹកជញ្ជូន?

ជឿន ៈ នៅរហូតដល់គេវៃដាច់ទីក្រុងភ្នំពេញ បានចូលមកភ្នំពេញ ។

ប៊ុនថន ៈ នៅហ្នឹងច្រើនទេអ្នកមីង ដែលខាងដឹកជញ្ជូនហ្នឹង?

ជឿន ៈ ពួកខ្ញុំតែ១០០នាក់ទេ ។

ប៊ុនថន ៈ ១០០នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជឿន ៈ ស្រីអត់ចាំស្រី ទាំងស្រីទាំងប្រុស១០០នាក់ អត់ចាំ ។

ប៊ុនថន ៈ កងដឹកជញ្ជូន ចុះដូចថាមានមេ ដូចថា១០០នាក់ហ្នឹងមានអ្នកគ្រប់គ្រងមួយ?

ជឿន ៖ អ្នកទទួលខុសត្រូវៗហ្នឹងគាត់ឡើងមកខ្សែត្រៀមហ្នឹង អីចឹងក៏យន្តហោះមក មកទៅក៏យន្តហោះបាញ់ បាញ់ស្លាប់ ។

ប៊ុនថន ៖ គាត់ឈ្មោះអីដែរ?

ជឿន ៖ ឈ្មោះ បេន បាញ់ចំត្រង់ហ្នឹង ប្រហោងគ្រហ៊ូ ស្លាប់តើស ។

ប៊ុនថន ៖ ហើយចុះអ្នកថ្មីឡើងមកទៀត?

ជឿន ៖ អ្នកថ្មីហ្នឹងក៏នៅក្រោមការគ្រប់គ្រងរបស់គាត់ ដូចថាបន្ទាប់ពីគាត់ស្លាប់ហ្នឹងចាស! ។

ប៊ុនថន ៖ អ្នកថ្មីឡើងមកជំនួសហ្នឹងឈ្មោះអីដែរ?

ជឿន ៖ ឈ្មោះ គី ហ្នឹងជនជាតិ ។

ប៊ុនថន ៖ ជនជាតិ ។

ជឿន ៖ ចាស! ប៉ុន្តែគាត់ស្លាប់បាត់ហើយ វៃកាលវៃនៅសំឡូត ស្លាប់បាត់ហើយ ។

ប៊ុនថន ៖ អូ! គាត់មកដល់ហ្នឹងដែរ?

ជឿន ៖ ចាស! នៅហ្នឹងដែរ ។ គាត់នៅខាងសំឡូត ។

ប៊ុនថន ៖ កាលហ្នឹងអ្នកមីងនៅកងដឹកជញ្ជូនហ្នឹង ការងាររាល់ថ្ងៃហ្នឹងដឹកជញ្ជូន បើយើងធ្វើ?

ជឿន ៖ ដឹកជញ្ជូនគ្រាប់ ។

ប៊ុនថន ៖ ដឹកជញ្ជូនគ្រាប់ពីណាទៅណាវិញ?

ជឿន ៖ ដឹកជញ្ជូនគ្រាប់ ប៉ុន្តែមិនដឹងចេញពីណាទេ គ្រាន់តែថាដឹកជញ្ជូនយកមកពីកំពង់ចាមទៅចែកតាមភូមិភាគ ។

ប៊ុនថន ៖ ភូមិភាគអីដែរអ្នកមីង?

ជឿន ៖ មិនដឹងភូមិភាគអីទេ ខ្ញុំអត់ចាំ អត់ចាំលេខទេ ។

ប៊ុនថន ៖ អីចឹងអ្នកមីងនៅកាណូតហ្នឹងម៉ង?

ជឿន ៖ ចាស!

ប៊ុនថន ៖ ដឹកគ្រាប់ចេញទៅ ។

ជឿន ៖ កាណូតហ្នឹងមានពួកយុវជនគេដឹកចេញទៅ តែខ្ញុំនៅមន្ទីរសម្រាប់ដេរខោអាវផ្គត់ផ្គង់នៅអង្គភាព ។

ប៊ុនថន ៖ នៅមន្ទីរវិញ?

ជឿន ៖ ចាស! តែនៅក្នុងអង្គភាពដឹកជញ្ជូនហ្នឹងដែរ?

ប៊ុនថន ៖ មន្ទីរខាងកាត់ដេរហ្នឹងប៉ុន្មាននាក់?

ជឿន ៖ គាត់ដេរ ខ្ញុំដេរតែពីរនាក់ ។

ប៊ុនថន ៖ តែពីរនាក់ទេ?

ជឿន ៖ ចាស! ពីរនាក់ទេបម្រើអង្គភាព ។

ប៊ុនថន ៖ អូ! ដេរមួយថ្ងៃៗ ។

ជឿន ៖ ដេរមួយថ្ងៃទល់ល្ងាចម៉ង ។

ប៊ុនថន ៖ បានប៉ុន្មានខោអាវដែរមីង?

ជឿន ៖ មួយថ្ងៃខ្ញុំដេរបានអាវ៥ អាវដៃវែង មួយថ្ងៃដេរបានអាវ៥ ដេរភ្ជាប់អីទាំងអស់ខ្លួនឯង ។

ប៊ុនថន ៖ ប៉ុន្តែមុនហ្នឹងមីងមានរៀនកាត់ដេរទេ?

ជឿន ៖ អត់ដែលរៀន ។

ប៊ុនថន ៖ ហើយធ្វើម៉េចចេះដេរ?

ជឿន ៖ មិនដឹង ដូចថាមាននិស្ស័យខាងកាត់ដេរ ដេរកើត ។ ចេញមកពីផ្ទះខ្ញុំអត់ចេះអីរលីង តែដូចថាចង់តែធ្វើការងារហ្នឹងម៉ង ។

ប៊ុនថន ៖ បាទ! ដេរម៉ាស៊ីនធាក់ជើង ឬក៏ដេរម៉ូទ័រ?

ជឿន ៖ ចាស! ម៉ាស៊ីនធាក់ជើង យើងតស៊ូខ្មែរក្រហមគ្មានម៉ូទ័រ គ្មានអីទេ ធាក់ជើងម៉ង ។

ប៊ុនថន ៖ ធាក់ជើងដេរ?

ជឿន ៖ ចាស! អត់មាន អ្នកមីងដេរយកម៉ង ដូចថាមានអាវមួយជាគំរូអីចឹងទៅ វាស់កាត់ថ្ងៃហ្នឹងវាស់កាត់ឲ្យច្រើនទៅ ហើយស្អែកឡើងចាប់ផ្ដើមដេរ ។

ប៊ុនថន ៖ ភ្ជាប់ម៉ង?

ជឿន ៖ ចាស! ភ្ជាប់យកម៉ង ។

ប៊ុនថន ៖ តែពីរនាក់?

ជឿន ៖ ម្នាក់បើគិតទៅថា មួយថ្ងៃអាវ១០ ហ្នឹងគ្នាពីរនាក់ ម្នាក់អ្នកភ្ជាប់កអីចឹងទៅ ភ្ជាប់កហើយដូចថាដេរកដេរអីហើយចឹងទៅ ម្នាក់ភ្ជាប់ស្មាទៅ ចេះដេរបន្តគ្នាឲ្យវិលទៅ វិលមកណាដោយមួយថ្ងៃហ្នឹងបានអាវ១០ តែពីរនាក់ទេ ។

ប៊ុនថន ៖ បានច្រើនដែរ ។ ចុះខាងមីងហ្នឹងគ្រប់គ្រងមេតែមួយទេ?

ជឿន ៖ ចាស! តែមួយទេ ។

ប៊ុនថន ៖ ដែរចុះមកមើលទេ?

ជឿន ៖ គាត់នៅផ្ទាល់ហ្នឹងម៉ង នៅផ្ទាល់អង្គភាពហ្នឹងម៉ង នៅធ្វើមន្ទីរតែមួយ ។

ប៊ុនថន :	មន្ទីរហ្នឹងនៅម្តុំណាដែរ?

ជឿន :	អូ! នៅច្រើនកន្លែងណាស់ ដើរនៅត្រពាស នៅគីគ្រីក៏នៅ នៅស្វាយរំពៀរ ហ្នឹងខេត្តកំពង់ឆ្នាំងហ្នឹង ស្រុកកំពង់លែងហ្នឹង ។ ចាស! ហ្នឹងស្រុកកំពង់លែងដែលខ្ញុំនៅ ពិសេសច្រើនខេត្តកំពង់ឆ្នាំង នៅគីគ្រី ជួនកាលឡើង ។ ក្រោយមកទៀត មុនដាច់ទីក្រុងភ្នំពេញខ្ញុំឡើងមកនៅបាធាយនេះ ។

ប៊ុនថន :	បាធាយ?

ជឿន :	បាធាយយើងនេះ ។

ប៊ុនថន :	បាធាយកំពង់ចាមយើង?

ជឿន :	បាទ! ដល់ដាច់នៅហ្នឹងទៅ ដាច់ទីក្រុងភ្នំពេញនាំគ្នាចូលទីក្រុងភ្នំពេញ ។

ប៊ុនថន :	ចុះអ្នកមីងនៅកន្លែងដឹកជញ្ជូនហ្នឹងចល័តកន្លែងរហូតអ្នកមីង?

ជឿន :	ចល័ត ដូចថាផ្លូវដឹកជញ្ជូនដូចមានទឹកច្រើនអីចឹងទៅឡានមិនអាចទៅបាន ចល័តកន្លែង ។

ប៊ុនថន :	ចល័តកន្លែងនៅម៉ង?

ជឿន :	កន្លែងមន្ទីរ ។

ប៊ុនថន :	ចុះមីងថាចល័តកន្លែងកំពង់ចាមហ្នឹងមកនៅឯណាវិញទៅ?

ជឿន :	មកនៅកំពង់ឆ្នាំង ។

ប៊ុនថន :	នៅកំពង់លែងហ្នឹងអ្វី?

ជឿន :	ចេញពីកំពង់ចាមមកហ្នឹងខ្ញុំមកនៅកំពង់ឆ្នាំង ហ្នឹងហើយមកនៅស្រុក១៦ហ្នឹង គេហៅស្រុកកំពង់លែង ហ្នឹងហើយស្រុកកំពង់លែង កាលសម័យហ្នឹងគេហៅស្រុក១៦ ។

ប៊ុនថន :	ស្រុក១៦?

ជឿន :	ចាស! កាលពីមុនមក កាលពីចាស់បុរាណគេហៅស្រុកកំពង់លែង ។

ប៊ុនថន :	មីងមកហ្នឹងមកទាំងប្រធានមីងអីមកហ្នឹងទាំងអស់?

ជឿន :	អត់ទេ ដូចថាក្នុងអង្គភាពហ្នឹងគេចាត់តាំងរើស កាលមក ចុះមកហ្នឹងគេរើសស្រីតែពីរនាក់ទេ ខ្ញុំម្នាក់ ហើយម្នាក់ទៀតហ្នឹងស្លាប់បាត់ហើយនៅខាងស្អីទេទៅត្បូងនេះ គេហៅមួយជួរភ្នំព្រឹកគេហៅស្អីទេ ខាងខ្មែម ។

ប៊ុនថន :	ខាងខ្មែម?

ជឿន :	ចាស! នៅខាងហ្នឹងឯង តែវាស្លាប់បាត់ហើយ ។

ប៊ុនថន :	បាទ! ទៅនៅ រើសទៅនៅកំពង់ឆ្នាំងពីរនាក់ហ្នឹង?

ជឿន :	ចាស!

ប៊ុនថន :	ទៅនៅហ្នឹងមីងកាត់ដេរដដែលអ្វី?

ជឿន :	កាត់ដេរដដែល តែពីលើហ្នឹងមកពីមុនហ្នឹងមកខ្ញុំអត់ដែលកាត់ដេរទេ ខ្ញុំនៅបម្រើវគ្គហ្នឹងអត់កាត់ដេរទេ ទាល់តែមកនៅកំពង់ឆ្នាំងនេះបានកាត់ដេរម៉ង ។ ខ្ញុំមិនដែលដេរទេ ទៅនៅហ្នឹងនៅគណៈមន្ទីរហ្នឹងគឺថា ជឿន ឯងដេរទៅ ព្រោះអីដូចថាឃើញខ្ញុំមាននិស្ស័យដេរតាំងពីសម័យកសាងមក ហើយប្រធានខ្ញុំ ប្រធានដែលថាគេបាញ់ស្លាប់ហ្នឹង យន្តហោះបាញ់ស្លាប់ហ្នឹងអត់ដែលស្គាល់ខ្ញុំទេ តែអ្នកដែលបន្ទាប់គាត់ គាត់ស្គាល់ខ្ញុំ ។ ចាស! គាត់ធ្លាប់ស្គាល់ខ្ញុំ គាត់ធ្លាប់ឃើញខ្ញុំដេរនោះ ដល់ឃើញដេរខោអាវបែកក្មេងៗ ដូចថាយុទ្ធនារីគ្នាឯង ដល់ទៅអីចឹងទៅ ដល់គាត់ដឹង គាត់ឲ្យដេរ ។

ប៊ុនថន :	ដេរទៅ មីងដេរមកពីហ្នឹង ដូចថាធ្លាប់ពីមុនមកដេរបែកគ្នាឯងចេះដេររហូត?

ជឿន :	ចាស!

ប៊ុនថន :	អីចឹងកាលនៅកំពង់ចាមហ្នឹងអត់ទាន់ដេរទេ នៅជាមួយអឹៗ?

ជឿន :	ចាស! នៅជាមួយអឹៗ ដាំបាយបម្រើវគ្គ ។

ប៊ុនថន :	បាទ! បាននៅកំពង់ឆ្នាំង?

ជឿន :	ចាស!

ប៊ុនថន :	នៅកំពង់ឆ្នាំងហ្នឹងប្រហែលជា មីងនៅរយៈពេលប៉ុន្មានមីង?

ជឿន :	មើលខ្ញុំចេញពីកំពង់ចាមមកចុងឆ្នាំ៧២ ខែប៉ុន្មានទេ ខ្ញុំមកនៅមួយឆ្នាំ៧៣ ចុង៧៣ ចូល៧៤ ខ្ញុំចេញមកនៅបាធាយ ។ អូ! ទៅនៅបាធាយ ទៅនៅកំពង់ឆ្នាំងដែរ នៅជិតព្រំប្រទល់កំពង់ស្ពឺ គេហៅភូមិស្អិត្រង់ណាទេ ឃុំច្រកត្នោត អាហ្នឹងសម្រាប់ទទួលអំបិល ។

ប៊ុនថន :	ទទួលអំបិល?

ជឿន :	ចាស!

ប៊ុនថន :	អំបិលហ្នឹងយកមកពីណាវិញ?

ជឿន :	ទទួលអំបិល អំបិលហ្នឹងគេដឹកមកពីស្រែអំបិលមក ដល់មកទុកនៅកន្លែងមន្ទីរពួកខ្ញុំហ្នឹង តែអ្នកដឹកនាំតែមួយទេ ។

ប៊ុនថន :	មីងចាំទទួលអំបិល?

ជឿន :	តែដូចថាខ្ញុំកូនក្រុមគេណា គ្រាន់នៅហ្នឹងទៅ គេអ្នកធ្វើការដាំបាយដាំទឹក គេហូបអីចឹងទៅណា ។

ប៊ុនថន : ហ្នឹងមីងចេញមកពីកំពង់ចាមមកនៅកន្លែងនេះសិន?

ជឿន : ចេញមកពីកំពង់ចាមមកនៅ ។

ប៊ុនថន : ដំបូងណា?

ជឿន : មកនៅកំពង់ឆ្នាំង ចេញពីកំពង់ឆ្នាំងហ្នឹងនៅកំពង់ឆ្នាំងដដែលហ្នឹង ប៉ុន្តែនៅច្រើនកន្លែង មាននៅភូមិស្វាយរំពៀរ នៅភូមិគុយ នៅភូមិកន្ថែប ចេញពីភូមិកន្ថែបបានខ្ញុំផ្លាយទៅកំពង់ឆ្នាំង ព្រំប្រទល់កំពង់ស្ពឺ ភូមិច្រកគ្នោតទទួលអំបិលហ្នឹង ។

ប៊ុនថន : ទទួលអំបិលហ្នឹង?

ជឿន : ចាស!

ប៊ុនថន : ហើយចុងក្រោយមីងឡើងមក?

ជឿន : ដល់ចុងក្រោយមកទៀតបានទៅបាធាយ ។

ប៊ុនថន : ហ្នឹងជិតដាច់ហើយ?

ជឿន : ហ្នឹងហើយជិតចូល៧៩ ។

ប៊ុនថន : ប៉ុន្តែនៅបាធាយហ្នឹងមីងកងង?

ជឿន : នៅកងដដែល ។

ប៊ុនថន : កងដដែល?

ជឿន : កងដដែល ។

ប៊ុនថន : ប៉ុន្តែកងដដែលហ្នឹង កងដេរ ឬមួយ?

ជឿន : មកនៅបាធាយខ្ញុំដេរដដែល បើនៅខាងទទួលអំបិលហ្នឹងអត់បានដេរទេ អត់មានម៉ាស៊ីនដេរទេអាហ្នឹង មកដល់បាធាយខ្ញុំដេរវិញដដែល ។

ប៊ុនថន : ចុះពេលដូរម្តងៗមានផ្លាស់ប្តូរមេគ្រប់គ្រងទេ ឬក៏ដដែល?

ជឿន : អត់ទេ មេក៏ដដែល ។

ប៊ុនថន : គណៈគ្រប់គ្រងហ្នឹងដដែល?

ជឿន : ដដែល កម្លាំងគ្នាឯងដដែល ស្គាល់គ្នាទាំងអស់ ។

ប៊ុនថន : ចុះមីងចង់ត្រឡប់ទៅដូចសួរមីងកាលនៅកំពង់ចាម មីងនៅជាមួយអ៊ីៗហ្នឹងណា មីងនៅជាមួយគាត់ក្នុងមន្ទីរជាមួយគាត់ចាំបម្រើអីចឹងអ្ហ៎?

ជឿន : មិនមែនទេលោកគ្រូ កន្លែងពួកខ្ញុំដូចសម្រាប់ដាំបាយអីចឹងនៅកន្លែងផ្សេង កន្លែងអ៊ីៗគាត់នៅផ្សេង ។

ប៊ុនថន :　គាត់នៅធ្វើការកន្លែងផ្សេង?

ជឿន :　កន្លែងផ្សេង ។

ប៊ុនថន :　ប៉ុន្តែឆ្ងាយពីគ្នា ឬមួយជិតគ្នា?

ជឿន :　មិនជាឆ្ងាយទេ ប្រហែលផ្ទះប្រធានភូមិមកនេះ ប៉ុន្តែនៅក្នុងព្រៃ ។

ប៊ុនថន :　អីចឹងអ៊ឹៗគាត់នៅច្រើនគ្នាទេ?

ជឿន :　អត់ទេ ពេលគាត់មកបើកអីចឹងគាត់មក ដល់បិទវគ្គអីចឹងចប់រៀនគាត់ទៅវិញហើយ អត់ដឹងគាត់ទៅកន្លែងណាទេ ខ្ញុំអត់ដឹងដែរ ។

ប៊ុនថន :　អីចឹងអ្នកមីងបានជួបគាត់បានជួបអីដែរ?

ជឿន :　ស្គាល់ ខ្ញុំស្គាល់ទាំងអស់ម៉ង ។

ប៊ុនថន :　កាលហ្នឹងអ្នកមីងស្គាល់នរណាខ្លះ?

ជឿន :　អ៊ឹ ប៉ុល ពត ក៏ខ្ញុំស្គាល់ អ៊ឹ អៀង សារី ទើបតែស្គាល់ក្រោយសម័យកសាងទេ ។ កាលនៅក្នុងព្រៃខ្ញុំអត់ដែលស្គាល់គាត់ទេ អត់ដែលឃើញគាត់ទេ ឃើញស្គាល់ៗបើថាស្និទ្ធស្នាលមែនទែន ធ្លាប់ស្គាល់ហៅអ៊ឹៗ អ៊ឹ នួន ជា ផ្អែមល្ហែមណាស់ជាមួយក្មួយៗ ខំធ្វើការ ខំរៀនអក្សរ ណែនាំ ។

ប៊ុនថន :　មានអ៊ឹ នួន ជា, ប៉ុល ពត មិញអ៊ឹ?

ជឿន :　ចាស! អ៊ឹ ប៉ុល ពត ស្គាល់មួងម្កាល?

ប៊ុនថន :　ចុះផ្សេងទៀតអ្នកមីង?

ជឿន :　អ៊ឹ ខៀវ សំផន ស្គាល់ មកស្គាល់ច្បាស់នៅទីក្រុងភ្នំពេញ បើអ៊ឹ នួន ជា ស្គាល់មុនគេ ។ ចាស! ស្គាល់គាត់ពេលគាត់ទៅបើកវគ្គបង្រៀន ។

ប៊ុនថន :　ចុះក្រៅពីហ្នឹងមានស្គាល់ទេ?

ជឿន :　ស្គាល់អ៊ឹៗប៉ុន្មាននាក់ហ្នឹងស្គាល់ទាំងអស់ គ្រាន់តែស្គាល់មុន និងក្រោយប៉ុណ្ណោះ ។

ប៊ុនថន :　ចុះនៅហ្នឹងដូចថាគណៈភូមិភាគអី អ្នកមីងអត់ដែលស្គាល់ទេ?

ជឿន :　អត់ស្គាល់ គណៈភូមិភាគអីអត់ដែលស្គាល់ទេ ស្គាល់តែអ៊ឹៗហ្នឹងឯង ។

ប៊ុនថន :　គាត់ខសប្ដាហ៍ចុះទៅប្រជុំប៉ុន្មានខែ?

ជឿន :　រៀន បើកវគ្គបង្រៀន បើតាមឋានៈ ដូចថាគណៈភាគអីចឹងរៀនកន្ទុះខែអីចឹងទៅ ឬក៏លើសកន្ទុះខែអីចឹងទៅ ហើយគណៈតំបន់រៀនកន្ទុះខែអីចឹងទៅ ។

ប៊ុនថន :　ប៉ុន្តែមកជុំគ្នាច្រើន?

ជឿន ៖ ចាស! ច្រើន ។

ប៊ុនថន ៖ ប្រហែលជាប៉ុន្មាននាក់ដែរពេលមកហ្នឹង?

ជឿន ៖ អត់ដឹងដែរ អត់ដឹងចំនួនប៉ុន្មាន បើពួកខ្ញុំគ្រាន់តែដាំបាយ មិនអាចឲ្យដឹងបានទេ ។

ប៊ុនថន ៖ ប៉ុន្តែដាំបាយដូចថាលើកទៅកន្លែងប្រជុំឲ្យគេពិសា?

ជឿន ៖ ចាស! មានផ្ទះគេមួយវែងធ្វើតុ ធ្វើអីអីចឹងទៅ មានអ្នកស្លផ្សេង មានអ្នកដាំបាយផ្សេង ។ ខ្ញុំដាំតែបាយទេ មិនដែលបានស្លទេ ជំនាញតែដាំបាយ ។

ប៊ុនថន ៖ ប៉ុន្មាននាក់ម៉ឹង?

ជឿន ៖ ដាំបាយគ្នាពីរនាក់ ។

ប៊ុនថន ៖ គ្នាពីរនាក់ដាំទាន់ដែរអ្នកម៉ឹង?

ជឿន ៖ ដាំទាន់ ឆ្នាំងធំៗ ឆ្នាំងៗណាស់ ម្នាក់ឯងដាំបានបីឆ្នាំង ឆ្នាំងធំៗ ចង្រ្កានក៏ស្រួលដុត អីក៏ស្រួលដុតដែរ ហើយទឹកគ្រាន់តែលាងអង្ករច្រក ហើយដួសទឹកចេញដ្បិទៅឆ្អិន ។

ប៊ុនថន ៖ ហើយអ្នកធ្វើម្ហូបប៉ុន្មាននាក់?

ជឿន ៖ អ្នកធ្វើម្ហូបគេគ្នាច្រើន មួយក្រុមម៉ង មួយក្រុម១២នាក់ម៉ង ចំណែកអ្នកដាំបាយគ្នាតិចទេ ។

ប៊ុនថន ៖ ចុះដូចអ្នកលើកម្ហូប អ្នករៀបចំអី?

ជឿន ៖ អ្នកលើកម្ហូប អ្នករៀបចំ អ្នកដាំបាយ និង អ្នកស្លហ្នឹងឯង ។

ប៊ុនថន ៖ ហ្នឹងឯងអ្នករៀបចំហ្នឹង ។ ចុះអ្នកម៉ឹងមានដែលទៅរៀបអីឲ្យគាត់ពិសាដែរទេ?

ជឿន ៖ បាយ អ្នកដាំបាយហូបបាយទៅ ធ្វើម្ហូបគេរៀបម្ហូប អ្នកដាំបាយដួសបាយរៀបដាក់តាមតុតែម្ដង ។

ប៊ុនថន ៖ ច្រើនទេ តុវែងទេ?

ជឿន ៖ តុដន្លែគ្នាប្អូនអីចឹងវែង វែងដែរហ្នឹងពីនេះទៅដល់ត្រង់នោះឯង ព្រោះរោងវាវែង មិនដល់១០០ទេ ព្រោះមេៗអីចឹងគេម្ហូប គេធ្វើហូបពីរ-បីមុខណោះ មិនមែនហូបមួយមុខៗឯណា ពីរ-បីមុខ ។

ប៊ុនថន ៖ ម្ហូបមានហូបអីខ្លះម៉ឹង?

ជឿន ៖ មានស្ងោរ មានឆាអីចឹងទៅតាមចុងភៅគេចេះច្នៃប្រឌិត ។

ប៊ុនថន ៖ អីចឹងម៉ឹងដូចថាពេលប្រជុំម្ដងៗអីចឹងវល់ទេ?

ជឿន ៖ ពេលបើកវគ្គហ្នឹង?

ប៊ុនថន : បាទ! ពេលបើកវគ្គម្ដងៗរវល់កន្លះខែអី?

ជឿន : មិនជារវល់អីទេ ព្រោះនៅកន្លែងហ្នឹងច្រើនក្រុម មិនមែនយើងដាំបាយរហូតទេ អត់ទេ ដូរគ្នា ថ្ងៃនេះខ្ញុំដាំ ស្អែកឡើងដូរ ។

ប៊ុនថន : អ្នកផ្សេងដាំវិញ?

ជឿន : ចាស! អ្នកផ្សេងដាំ ។

ប៊ុនថន : ចុះដល់ពេលអ្នកមីងអត់ដាំអីចឹង អ្នកមីងធ្វើអី សម្រាក ។

ជឿន : អ្នកអត់ដាំបាយទៅឧស ។

ប៊ុនថន : ទៅរកឧសវិញ?

ជឿន : ចាស! ឬក៏ទៅបេះស្លឹកមកដេរ ។

ប៊ុនថន : ចុះដល់ពេលចេញមក ដូចថាមកអីចឹងមីងមានដែលទាក់ទងទៅផ្ទះវិញទេ មានដែលសរសេរសំបុត្រអីផ្ញើទៅផ្ទះទេ?

ជឿន : ផ្ទះកំណើត?

ប៊ុនថន : បាទ!

ជឿន : អត់ តែចេញមកអត់ដែលទាក់ទងទេ នៅហ្នឹងអត់ដែលបានទៅ ទៅផ្ទាល់ម៉ង អត់ចាំបាច់សរសេរសំបុត្រទេ ។

ប៊ុនថន : ហើយអឹៗហ្នឹងឧស្សាហ៍និយាយ ឧស្សាហ៍ជួបមីងផ្ទាល់ដែរ និយាយថាឲ្យខំរៀនហ្នឹង?

ជឿន : ជួប ទៅពេលម៉ោងគាត់សម្រាកអីចឹង ដូចថាមេៗដែលគេឈប់រៀនអីចឹង គាត់ឆ្លៀតយកម៉ោងហ្នឹងមកបង្រៀនពួកខ្ញុំ ។

ប៊ុនថន : បង្រៀនទៀត?

ជឿន : បង្រៀនខ្ញុំអឹ នួន ជា គាត់បង្រៀនអប់រំពីនយោបាយអីហ្នឹងណា ។

ប៊ុនថន : បង្រៀនមីង ហើយក្រុមពួកអ្នកដាំបាយប៉ុន្មាននាក់?

ជឿន : ក្រុមដាំបាយហ្នឹងគ្នាបីក្រុម ពេញមួយក្រុមហ្នឹងវា១២នាក់ណា វាជាង៣០នាក់ហើយ ហ្នឹងសម្រាប់តែនារីៗ យុទ្ធជនផ្សេង យុទ្ធជនពួកកងការពារ ។

ប៊ុនថន : បង្រៀនហ្នឹងគាត់បង្រៀនអីខ្លះ?

ជឿន : គាត់បង្រៀនអប់រំឲ្យតែយើងខំធ្វើការងារល្អអី ហើយយប់ៗឆ្លៀតរៀនសូត្រអក្សរ ឲ្យចេះអានចេះអី ។

ប៊ុនថន : ប៉ុន្តែមីងមានបានរៀនទេ? គាត់មានបានបង្រៀនអក្សរអីទេ?

ជឿន : អត់បានបង្រៀនអក្សរទេ គាត់ពន្យល់ណែនាំដូចថា អានេះយើងធ្វើយ៉ាងម៉េចៗ ខ្ញុំមិនសូវចេះថានយោបាយគាត់ណែនាំខាងផ្នែកនយោបាយអីចឹងណា ខ្ញុំមិនសូវយល់ទេ ។ គាត់ណែនាំៗថា ធ្វើឲ្យល្អកុំខ្ជិលច្រអូសហ្នឹងការងារអី ក្នុងការរស់នៅអី រឿងប្រាស្រ័យទាក់ទង យើងរស់នៅសីលធម៌ឲ្យស្អាតស្អំអីចឹងទៅណា ។

ប៊ុនថន : គាត់ឧស្សាហ៍មកដូចថាអប់រំ?

ជឿន : ចាស! ដូចថាអប់រំជាប់ណែនាំតែរឿងល្អ ហើយការហូបចុកអីចឹងទៅ នាំគ្នាហូបបាយឲ្យហូបឲ្យគ្រប់គ្រាន់ឲ្យឆ្អែត ខ្លាចឈឺគ្រុនអីចឹងណា ។

ប៊ុនថន : គាត់ឧស្សាហ៍ជួបច្រើនដងដែលអ្នកមីង?

ជឿន : ចាស!នៅពេលបើវគ្គជួប ។

ប៊ុនថន : បាទ ។

ជឿន : ដល់កន្លែងគាត់ផ្សេងៗខ្ញុំមិនសូវដឹងដែរ ជួបតែពេលបើកវគ្គទេ ។

ប៊ុនថន : បាទ ។

ជឿន : តែខ្ញុំនៅរយៈខ្លីទេ ខ្ញុំចុះមកដឹកជញ្ជូនខ្ញុំនៅរយៈខ្លីខ្ញុំនៅប្រហែលជាពីរខែ ។

ប៊ុនថន : គេចាត់តាំងមីង?

ជឿន : ចាស!គេចាត់តាំងជ្រើសរើសដូចថាខាងទន្លេសាបហ្នឹងគេខ្វះកំលាំងនារីចឹងទៅ គេខ្វះកំលាំងនារីរឿងដាំស្លសម្រាប់ឲ្យយុទ្ធជនចឹង ។

ប៊ុនថន : បាទ ។

ជឿន : ចាស!គេដកមកៗហើយមកហ្នឹងមិនមែនចេះតែឲ្យមកទេ គេជ្រើសរើអ្នកព្យាយាមបានឲ្យមក ។

ប៊ុនថន : បាទ ។

ជឿន : អ្នកខ្ជិលច្រអូសមិនឲ្យមកទេ ។

ប៊ុនថន : បាទ ។

ជឿន : ទាល់តែម្នាក់ចត់ហ្នឹងការងារបានគេឲ្យមក ។

ប៊ុនថន : ចឹងមីងចេញមកហ្នឹងមកស្រុក១៦ហ្នឹងតែម្ដង?

ជឿន : ចាស!មកស្រុក១៦តែម្ដងជិះកាណូតឡើងមួយយប់ទាល់ភ្លឺ ឡើងឆ្លងកាត់ណាណីទេខ្ញុំមិនបានចំណាំទេដើរយប់ ។

ប៊ុនថន : ជិះពេលយប់?

ជឿន ៖ ចាស!ជិះពេលយប់ ។

ប៊ុនថន ៖ យ៉ាងម៉េចបានជាជិះពេលយប់ចឹង?

ជឿន ៖ ចុះការណ៍ពួកប្រជាជនចេញមកចឹងចេះតែជិះចេញមកទៅ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!ដូចថាយើងចេញពីកំពង់ចាមហ្នឹងទៅពេលយប់ ដល់ទៅដល់ហ្នឹងទំរាំទាក់ទងគេបានចេញចឹងចេញយប់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចឹងកាលហ្នឹងខ្លាចយន្តហោះនោះ យន្តហោះបាញ់តែឃើញថ្ងៃមិនបានទេ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ខ្ញុំចង់សាប់ចង់រស់ដែលកាលហ្នឹងជីកគ្រាប់ដីកអីតាមហ្នឹង ស៊ីងជីនិតហ្នឹង ស៊ីងជីនិតទៅពីកំពង់ថ្មទៅហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ យន្តហោះបាញ់ចង់សាប់ចង់រស់ ។

ប៊ុនថន ៖ តែមិនត្រូវមីងទេ?

ជឿន ៖ អត់ត្រូវទេ កាលហ្នឹងអំបែងឲ្យប្រាវៗគ្រាបនៅក្នុងទូកហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ បើសិនជាទម្លាក់ចំទូកត្រូវសាប់ទាំងអស់ ចុះគ្រាប់ពេញទូកហ្នឹងឯង ។

ប៊ុនថន ៖ ចឹងចង់សួរអ្នកមីងបន្តពេលមកនៅបាធាយវិញអ្នកមីង កាលនៅបាធាយហ្នឹងនៅយូរដែរ?

ជឿន ៖ នៅបាធាយខ្ញុំមិនសូវយូរប៉ុន្មានទេ ខ្ញុំមកពីកំពង់ឆ្នាំងព្រំប្រទល់កំពង់ស្ពឺមកនៅហ្នឹងដូចជាអត់យូរប៉ុន្មានទេ កាលគេវៃដាច់នាមគ្នាចូលមក ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ អត់បានទៅយូរទេ ។

ប៊ុនថន ៖ ចឹងកាលចូលមកភ្នំពេញហ្នឹងមីងមកខាងអីវិញ?

ជឿន ៖ ចូលមកភ្នំពេញដំបូងហ្នឹងគេឲ្យខ្ញុំមកដេរស្រោមក្នើយកន្ទែងអីៗទៀត ។

ប៊ុនថន ៖ កន្ទែងអីៗ?

ជឿន ៖ ចាស!កន្ទែងអីៗខៀវ សំដនហ្នឹង ។

ប៊ុនថន ៖ នៅមុំណាអ្នកមីង?

ជឿន ៖ នៅក្នុងវាំងតែម្ដង ។

ប៊ុនថន ៖ នៅក្នុងវាំង?

ជឿន ៖ ចាស!ចូលនៅក្នុងវាំងតែម្ដងអ្នកដឹកនាំអង្គភាពខ្ញុំចាស់ហ្នឹង គេថាខ្ញុំហ្នឹងចេះដេរយកមកឲ្យដេរស្រោមក្នើយ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មកដេរជាមួយបុរសម្នាក់ជនជាតិលាវ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ តែពីរនាក់ហ្នឹងឯង ខ្ញុំមិនចេះនៅទេខ្ញុំទៅនៅកន្លែងចាស់ខ្ញុំវិញ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដល់នៅកន្លែងចាស់ដូចក្រោយមកទៀតមានភ្ញៀវច្រើន ចិនចុះមកច្រើនណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេយកខ្ញុំទៅដាំបាយឲ្យភ្ញៀវទៀត ។

ប៊ុនថន ៖ ចឹងមីងចូលដំបូងហ្នឹងនៅក្នុងវាំងតែម្ដងនៅកន្លែងដេរ?

ជឿន ៖ ចាស!នៅក្នុងវាំងតែម្ដង ។

ប៊ុនថន ៖ ចឹងនៅខាងជាមួយ?

ជឿន ៖ ជាមួយអីៗហ្នឹង ។

ប៊ុនថន ៖ នៅជាមួយខៀវ សំផន?

ជឿន ៖ មានអីនួន ជា ឃើញតែអីនួន ជា អីប៉ុន្មាននាក់ទៀតមិនឃើញទេ ឃើញអីនួន ជាហ្នឹងហើយដាំងគេ ។

ប៊ុនថន ៖ បាទ!តែគាត់ស្គាល់ដែលនៅពេលជួប?

ជឿន ៖ ខ្ញុំមិនស្គាល់ទេ ព្រោះខ្ញុំមិនបាននៅស្និតស្នាលដូចបងស្រីខ្ញុំនៅខាងកាចាប់ហ្នឹងគាត់នៅផ្ទាល់គាត់ស្គាល់គ្រាន់តែឃើញហៅតែម្ដង ពួកខ្ញុំគាត់មិនស្គាល់ទេ តែខ្ញុំស្គាល់គាត់ គាត់មិនស្គាល់ខ្ញុំទេ ព្រោះគ្នាច្រើនពេក ។

ប៊ុនថន ៖ ចឹងកាលមីងមកនៅជាមួយគាត់ហ្នឹងមីងមិននិយាយប្រាប់គាត់ថាធ្លាប់ជួបនៅកំពង់ចាមអីទេ?

ជឿន ៖ អត់ ។

ប៊ុនថន ៖ អត់ដែលហ៊ាននិយាយ?

ជឿន ៖ ចាស!មិនដែលហ៊ាននិយាយ ។

ប៊ុនថន ៖ នៅក្នុងវាំងហ្នឹងនៅក្នុងរបងវាំងតែម្តងមែន?

ជឿន ៖ នៅក្នុងរបងវាំងកន្លែងប្រាសាទព្រះកែវនោះ ។

ប៊ុនថន ៖ ប្រាសាទព្រះកែវមរកតហ្នឹង?

ជឿន ៖ ចាស!នៅក្នុងហ្នឹងតែម្តង នៅក្នុងរបងហ្នឹងក្នុងប្រាសាទហ្នឹងក៏មិនហ៊ានចូលដែរ ព្រោះជាប់សោអត់មានចូលបានទេ ។

ប៊ុនថន ៖ ចឹងចាក់សោ?

ជឿន ៖ ចាស!កាលហ្នឹងចាក់សោខ្ញុំនៅក្នុងហ្នឹងឯង ។

ប៊ុនថន ៖ នៅក្រៅហ្នឹងនៅក្នុងអាគារថ្មឬមួយនៅក្នុងផ្ទះ?

ជឿន ៖ នៅក្នុងរោងវែងៗព័ទ្ធជុំវិញរបងហ្នឹង ។

ប៊ុនថន ៖ រោងឈើមែន?

ជឿន ៖ អត់ទេ រោងស៊ីម៉ងត៍តែម្តង គេធ្វើរោងវែងព័ទ្ធជុំវិញរបងនោះរបងវាំងហ្នឹងមិនមានព័ទ្ធឃឿនវាព័ទ្ធជុំវិញ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ហើយគេធ្វើមានរោងវែងចឹងទៅ ពួកខ្ញុំនៅហ្នឹងឯងមិនហ៊ានទៅក្នុងផ្ទះទេ ។

ប៊ុនថន ៖ យ៉ាងម៉េចបានជាមិនហ៊ាននៅ?

ជឿន ៖ ចុះខ្លាចកាលនោះចូលទីក្រុងភ្នំពេញដំបូង វាអត់ស្រួលព្រោះខ្លាចមានពួកចាហ៊ានអីនៅ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!ខ្លាចចាហ៊ាននៅម៉ោង១យប់ឬម៉ោង១២ហ្នឹងផ្ទះអាវុធ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ផ្ទុះអាវុធហ្នឹងអឺៗហ្នឹងគាត់មកដាស់ខ្ញុំថា ក្មួយៗក្រោកឡើងកុំដេកខ្លាចហើយដល់នេះយើងព្រួសផ្ទះឆេះផ្ទះនោះទៅឡានទឹក ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ព្រួតែឡានសេរ៉ែន ។

ប៊ុនថន ៖ ចឹងកាលដំបូងមិនទាន់ស្រួលបួលដែរ?

ជឿន ៖ អត់ទេស្រួលទេ នៅវៃគ្នាហ្នឹងអសន្តិសុខអត់មានសន្តិភាពអីផង ។

ប៊ុនថន ៖ ចឹងអ្នកមីងនៅហ្នឹងគ្នាច្រើនទេ អ្នកមីងនៅក្នុងវាំងហ្នឹង?

ជឿន ៖ ដូចជាមិនច្រើនប៉ុន្មានទេ កងការពារអីៗប៉ុណ្ណឹងឯងនិងអ្នកដាំបាយឲ្យគាត់ហើយខ្ញុំគ្រាន់ជាអ្នកដេរស្រោមក្នើយឲ្យគាត់គ្នាពីរនាក់ ។

ប៊ុនថន ៖ ចឹងគ្នាពីរនាក់?

ជឿន ៖ ចាស!ខ្ញុំមិនបានដឹងថាមានចំនួនប៉ុន្មានមិនដឹងទេ ។

ប៊ុនថន ៖ ចឹងនៅហ្នឹងគាត់ជាអ្នកគ្រប់គ្រងផ្ទាល់តែម្តង?

ជឿន ៖ មិនដឹងជាអ្នកណាគ្រប់គ្រងតែអីៗគាត់ចេះតែអប់រំ ។

ប៊ុនថន ៖ គាត់មានដែលចុះមកមើលដែលអ្នកមីង?

ជឿន ៖ ចាស!ឃើញ ឃើញផ្ទាល់ ។

ប៊ុនថន ៖ ចឹងមីងសេរស្រោមក្នើយហ្នឹងគាត់មកមើលផ្ទាល់?

ជឿន ៖ ដេរហ្នឹងគាត់មិនមកមើលទេ មានគណៈកម្មការផ្សេងគេមកមើលត្រួតពិនិត្យផ្សេង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ស្រោមក្នើយហ្នឹងដេរសម្រាប់ដូចថាយកទៅដាក់ស្រោមក្នើយឲ្យភ្ញៀវតាមផ្ទះហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មានដេរវាំងននអីចឹង ។

ប៊ុនថន ៖ ចឹងអ្នកដេរជាមួយមីងលាវហ្នឹងគាត់ចេះខ្មែរដែរ?

ជឿន ៖ លាវហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចេះខ្មែរ ។

ប៊ុនថន ៖ ចេះខ្មែរដែរ?

ជឿន ៖ ចាស!ព្រោះគាត់មកតាំងពីតូចនោះ ។

ប៊ុនថន ៖ ចឹងនៅក្នុងវាំងនៅហ្នឹងក្រៅពីមីងនៅហ្នឹងមានអ្នកផ្សេងដូចជាស្តេចគង់នៅហ្នឹងទេ?

ជឿន ៖ អត់ទេ ។

ប៊ុនថន ៖ ចឹងមីងអត់ឃើញទេ?

ជឿន ៖ អត់ឃើញ អត់មានឃើញទេ ។

ប៊ុនថន ៖ ចឹងមីងនិយាយមិញថាមានភ្ញៀវចិនអីនោះ?

ជឿន ៖ ក្រោយមកទៀតបានភ្ញៀវចិនគេចុះមកកម្មករចិនច្រើន ចុះមកទៅខ្ញុំហ្នឹងទៅដាំបាយឲ្យភ្ញៀវទៅ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ បើភ្ញៀវកម្មករផ្សេងៗខ្ញុំមិនបានដាំបាយទេ ដាំបាយឲ្យភ្ញៀវគេចុះមកបង្រៀនថត ថតរូប ថតកុនអីចឹងទៅណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ខ្ញុំនៅហ្នឹងបានយូរ នៅទាល់តែគេបិតវគ្គថតបានចេញទៅវិញបានខ្ញុំមកអគ្គភាពខ្ញុំវិញ ខ្ញុំនៅជិតវាំងហ្នឹងដែរ ។

ប៊ុនថន ៖ ចឹងអ្នកមីងនៅហ្នឹងមានបានថតអីដែរ?

ជឿន ៖ អត់ បានតែដាំបាយឲ្យភ្ញៀវ ។

ប៊ុនថន ៖ ភ្ញៀវចិនមកបង្រៀនថតហ្នឹង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ បង្រៀនហ្នឹងបង្រៀនពីណាវិញ?

ជឿន ៖ បង្រៀនពួកដូចថាគេដកតាមកងពល ដកតាមកងពលចឹងដូចថាពីណាដឹកនាំគេត្រឹមមេកង កងវរយប្ញកងវរៈអីចឹងមកបង្រៀន ។

ប៊ុនថន ៖ មករៀនថតហ្នឹង?

ជឿន ៖ ចាស!មករៀនថត ។

ប៊ុនថន ៖ មកច្រើនទេចិនៗ?

ជឿន ៖ ចិនមកបង្រៀនថតហ្នឹងមានគ្នា១០នាក់ ។

ប៊ុនថន ៖ ចឹងមាន១០នាក់?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងមកបង្រៀននៅក្នុងវាំងហ្នឹងតែម្ដង?

ជឿន ៖ អត់ទេ បង្រៀនមកជិតផ្លូវសាលាសកលវិទ្យាល័យនោះ ផ្ទះហ្នឹងជិតសាលាកន្លែងពីមុនខ្ញុំមិនដឹងគេហៅ ។

ប៊ុនថន ៖ សាលារចនា?

ជឿន ៖ អត់ទេ ជាប់ទៅទួលគោកជិតថ្នល់រទេះភ្លើងហ្នឹង ។

ប៊ុនថន ៖ សាលាភូមិន្ទភ្នំពេញ?

ជឿន ៖ ពីមុនមកមិនដឹងជាគេហៅសាលាអីទេត្រង់ហ្នឹង ដល់សម័យកសាងគេហៅសាលាបច្ចេកទេសខ្មែរសូវៀត ។

ប៊ុនថន : ហ្នឹងហើយឥឡូវគេហៅសាលាទិចណូ?

ជឿន : ចឹង ។

ប៊ុនថន : បាទ ។

ជឿន : ហ្នឹងហើយខ្ញុំមកដាំបាយឲ្យភ្ញៀវនៅមុំត្រង់ហ្នឹង ។

ប៊ុនថន : ចឹងមីងចេញពីវាំងហើយ?

ជឿន : ចេញពីវាំងហើយ ។

ប៊ុនថន : ចឹងមីងសុំចេញឬមួយគេចាត់តាំង?

ជឿន : គេចាត់តាំងតែម្ដង ។

ប៊ុនថន : គេចាត់តាំងឲ្យមកដាំបាយឲ្យភ្ញៀវ?

ជឿន : ចាស!គេចាត់តាំងអ្នកចាត់តាំងខ្ញុំហ្នឹងគាត់នៅនេះតែគាត់ចាស់ហើយ ហៅគាត់ គាត់អត់ស្គាល់គាត់ថាស្ដាប់មិនបានទេ សម្ដេងមិនដឹងពីណាពីណីទេ ។

ប៊ុនថន : គាត់ឈ្មោះអីវិញ?

ជឿន : គាត់ឈ្មោះ ហុង ។

ប៊ុនថន : ឈ្មោះ ហុង?

ជឿន : ចាស ។

ប៊ុនថន : ចឹងប្រុស?

ជឿន : ប្រុស!គាត់ចាស់ហើយឡើងសក់សអស់ហើយ ខ្ញុំថាបងអត់ស្គាល់ខ្ញុំទេ គាត់ថាដឹងណាណីទេ អូនអើយគ្នាច្រើនពេកមិនដឹងពីណាពីណីទេ ។

ប៊ុនថន : បាទ!កាលហ្នឹងគាត់ជាអ្នកគ្រប់គ្រង?

ជឿន : គាត់ហ្នឹងដូចថាជាលេខារបស់តាៗហ្នឹងណាស់ ។

ប៊ុនថន : ចឹងអ្នកមីងនៅដេរស្រោមក្ញើយហ្នឹងបានរយៈពេលប៉ុន្មាន?

ជឿន : ខ្ញុំនៅអត់យូរដែរខ្ញុំនៅបានប្រហែលជា១០ថ្ងៃ ។

ប៊ុនថន : ចឹង១០ថ្ងៃបានមកដាំបាយ?

ជឿន : ចាស!ខ្ញុំមកនៅអគ្គភាព អគ្គភាពហ្នឹងគេហៅដំណាក់និរសា ។

ប៊ុនថន : ដំណាក់និរសា?

ជឿន : ចាស!ដល់ចេញពីកន្លែងហ្នឹង ខ្ញុំទៅបោសសម្អាតផ្ទះដើម្បីភ្ញៀវមកស្នាក់នោះ ។

ប៊ុនថន : បាទ ។

ជឿន ៖ ដល់ខ្ញុំបោសសម្អាតមិនទាន់ហើយផង គេយកខ្ញុំទៅដាំបាយនៅកន្លែងផតហ្នឹង ។

ប៊ុនថន ៖ បោសសម្អាតផ្ទះនៅណា?

ជឿន ៖ នៅភ្នំពេញហ្នឹង ។

ប៊ុនថន ៖ នៅកន្លែងណាខ្លះមីង?

ជឿន ៖ នៅមុំកន្លែងហ្នឹងមិនគេហៅស្អីទេ ខ្ញុំអត់ស្គាល់ដែលកន្លែងហ្នឹងផ្ទះកោង១ហ្នឹងទល់មុខស្ថានីយ៍រទេះភ្លើង កន្លែងហ្នឹងនៅជាប់មន្ទីរ"ដប៉ុន្មានទេ" ត្រង់ហ្នឹងខ្ញុំអត់ចាំដែរ ។

ប៊ុនថន ៖ កន្លែងបោសហ្នឹងជាសណ្ឋាគារឬមួយផ្ទះល្វែងមីង?

ជឿន ៖ ផ្ទះល្វែងដឹងវាមិនសូវស្គាល់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ហើយផ្ទះដែលខ្ញុំនៅហ្នឹងមិនដឹងជាគេហៅផ្ទះស្អីទេ ផ្ទះហ្នឹងរាងកោង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេហៅផ្ទះកោង១ ។

ប៊ុនថន ៖ ផ្ទះកោង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងទៅបបោសនៅហ្នឹងឲ្យភ្ញៀវស្នាក់នៅមីង?

ជឿន ៖ ចាស!បបោសឲ្យស្អាតឲ្យភ្ញៀវមកស្នាក់មកទាំងយន្តហោះមកចុះមកច្រើនតែម្តង ។

ប៊ុនថន ៖ ភ្ញៀវមកពីណា?

ជឿន ៖ ភ្ញៀវចិន ។

ប៊ុនថន ៖ ភ្ញៀវចិន?

ជឿន ៖ ចាស ។

ប៊ុនថន ៖ និយាយថាពេលមកហ្នឹងមីងនិយាយថាឃើញដឹកឡានមកហ្នឹង?

ជឿន ៖ ឃើញចុះពីលើយន្តហោះមកជិះឡានមកចូលមកនៅកន្លែងពួកខ្ញុំរៀប ។

ប៊ុនថន ៖ ចឹងអ្នកមីងរៀបចំបោសសម្អាត?

ជឿន ៖ ចាស!រៀបចំបោសសម្អាតអីចឹង ។

ប៊ុនថន ៖ ចឹងក្រៅពីភ្ញៀវចិនមកមានភ្ញៀវអីផ្សេងទៀតទេអ្នកមីង?

ជឿន ៖ ខ្ញុំអត់ដឹងទេ ខ្ញុំអត់ដឹងដែរ ខ្ញុំធ្លាប់ស្គាល់តែភ្ញៀវចិន ។

ប៊ុនថន ៖ ចឹងមកម្តងច្រើននាក់ទេមីង?

ជឿន ៖ ច្រើន ។

ប៊ុនថន ៖ ចឹងមីងនៅខាងរៀបចំហ្នឹងចុះខាងដាំបាយទឹកហូបអីមានផ្សេងទៀតអ្នកមីង?

ជឿន ៖ ខាងរៀបចំ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដាំបាយរៀបតាមកង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដូចថាមួយកងមានគ្នា៣០នាក់ចឹងទៅ មានអ្នកដាំបាយមានអ្នកទៅរៀប ។

ប៊ុនថន ៖ ដាំឲ្យភ្ញៀវហ្នឹង?

ជឿន ៖ អត់ទេ ភ្ញៀវមានចុងភៅគេផ្សេង ភ្ញៀវមានចុងភៅគេចេះធ្វើម្ហូបធ្វើអីហ្នឹងផ្សេង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ពួកខ្ញុំអ្នករៀបផ្ទះហ្នឹងមួយកងៗដាំបាយហូបរៀងៗខ្លួន ។

ប៊ុនថន ៖ មានច្រើននាក់ដែលអ្នកមីងអ្នករៀបចំ?

ជឿន ៖ មានច្រើនពីរកងនោះ ។

ប៊ុនថន ៖ មួយកងមានប៉ុន្មាននាក់?

ជឿន ៖ មួយកងមាន៣០នាក់ ។

ប៊ុនថន ៖ ចឹងពីរកងមាន៦០នាក់?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងមានច្រើនបន្ទប់មីងដែលត្រូវរៀបចំ?

ជឿន ៖ ជួនកាលមួយផ្ទះវែងចឹងមានប៉ុន្មានបន្ទប់ខ្ញុំអ្នករៀបទាំងអស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ អ្នកណារៀបបោសហើយចឹងមានអ្នកមកជូត មានអ្នករៀបមានជូតស្អីៗកំទេចអីបោសចេញឲ្យអស់ ជូតឲ្យស្អាតហើយមានអ្នករៀបគ្រែ ប្រុសៗមករៀបគ្រែ ។

ប៊ុនថន ៖ ចឹងមីងមានដឹងថាភ្ញៀវហ្នឹងគាត់មកធ្វើអីដែលមីង?

ជឿន ៖ កម្មករមកធ្វើរោងចក្រ ។

ប៊ុនថន ៖ មកធ្វើរោងចក្រ?

ជឿន ៖ ចាស!មានកម្មករកំពង់ផែមានកម្មករធ្វើរោងចក្រ រឿងកម្មករទៅធ្វើអីខ្ញុំមិនសូវដឹងទេ តែដឹងថាកម្មករគេមកធ្វើហ្នឹងតែម្តង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ តែមិនបានដឹងថាគេធ្វើស្អី ខ្ញុំមិនបានដឹងដែរ ។

ប៊ុនថន ៖ ចឹងមីងនៅខាងបោសសម្អាតហ្នឹងបានប៉ុន្មាន?

ជឿន ៖ នៅខាងបោសសម្អាតខ្ញុំនៅបានរយៈខ្លី នៅយូរជាងគេខ្ញុំទៅនៅកន្លែងដាំបាយឲ្យភ្ញៀវថតយូរ ជិតមួយឆ្នាំ ។

ប៊ុនថន ៖ ជិតមួយឆ្នាំ?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងអ្នកគ្រប់គ្រងដដែល?

ជឿន ៖ អត់ទេ អ្នកគ្រប់គ្រងផ្សេងទៀតខ្ញុំអត់ស្គាល់ដែរ ។

ប៊ុនថន ៖ ខាងដាំបាយឲ្យអ្នកថតរូប?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងពេលមករៀន រៀននៅណាវិញមីង រៀននៅសាលាហ្នឹងតែម្តង?

ជឿន ៖ រៀននៅផ្ទះអត់មានសាលាទេ ។

ប៊ុនថន ៖ រៀននៅផ្ទះ?

ជឿន ៖ ហ្នឹងហើយទទឹមគ្នាដូចខ្ញុំថាផ្ទះខ្មែរសូរវៀតហ្នឹងណាស់ ម៉ាជិនារហ្នឹងឯង ។

ប៊ុនថន ៖ នៅទល់មុខគ្នា?

ជឿន ៖ អត់ទល់មុខគ្នាទេ ផ្ទះម៉ាជួរគ្នាហ្នឹងដូចថារបងខាន់ៗណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ សាលាបច្ចេកទេសនៅខាងចេះទៅ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ហើយមកខាងក្រៅហ្នឹងមានផ្ទះមួយទៀត ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ នៅហ្នឹងតែម្តង ។

ប៊ុនថន ៖ អាគារថ្មហ្នឹង?

ជឿន ៖ អាគារថ្ម ។

ប៊ុនថន ៖ ចឹងមីងដាំបាយនៅហ្នឹងអ្នករៀនថតនៅហ្នឹង?

ជឿន ៖ ចាស!អ្នករៀនថតៗទៅខ្ញុំដាំបាយ ។

ប៊ុនថន : ច្រើនទេអ្នកមករៀនហ្នឹង?

ជឿន : អ្នករៀនថតមានគ្នា៣០ទៅ៤០នាក់ដែលដឹងយកគ្រប់ភូមិភាគ យកតាមភូមិភាគនិរតីភូមិភាគអីខ្លះទេ មកតាំងពីព្រៃវែង តាកែវអីចឹងណាស់ ។

ប៊ុនថន : បាទ ។

ជឿន : អ្នកកំពង់ធំអីចឹងទៅ គេរើសតាមកផលហ្នឹងគេយកមករៀននៅហ្នឹងយកមកឲ្យចិនបង្រៀនហ្នឹង ។

ប៊ុនថន : បង្រៀនរយៈពេលប៉ុន្មានអ្នកមីងម្តងៗ?

ជឿន : បង្រៀនខ្ញុំថាអត់ដល់មួយឆ្នាំទេ តែខ្ញុំនៅជិតមួយឆ្នាំ ។

ប៊ុនថន : តែអ្នកមកម្តងមួយវគ្គ?

ជឿន : អត់ទេ បើកតែមួយវគ្គហ្នឹងឯង ។

ប៊ុនថន : ចឹងមានតែមួយវគ្គទេ?

ជឿន : ចាស!ដូចថាមនុស្សមកពីកផលពីរនាក់ហ្នឹងមកតែពីរនាក់ហ្នឹង អត់មានដូរគ្នាទេ ។

ប៊ុនថន : ចឹងដល់ចប់ទៅវិញតែម្តង?

ជឿន : ចាស!ចប់ទៅវិញតែម្តង ។

ប៊ុនថន : ចឹងនៅហ្នឹងអ្នកគ្រប់គ្រងមីងផ្សេងទៀត?

ជឿន : ផ្សេងទៀតអត់ស្គាល់ទេ ខ្ញុំអត់ស្គាល់មិនដឹងឈ្មោះអី ។

ប៊ុនថន : ចឹងចិនៗមីងមានស្គាល់ទេ ដូចថាអ្នកមកបង្រៀនណាស់?

ជឿន : អ្នកមកបង្រៀនខ្ញុំស្គាល់ច្បាស់តែពីរនាក់ មួយឈ្មោះ តា ហៃ ។

ប៊ុនថន : តា ហៃ?

ជឿន : ចាស! មួយទៀតឈ្មោះ តា ស៊ា មានបីនាក់មាន តា ប៉ុកមួយទៀត ។

ប៊ុនថន : តា ពក?

ជឿន : តា ប៉ុក ។

ប៊ុនថន : គាត់ចេះខ្មែរដែរ?

ជឿន : បើតា ស៊ាហ្នឹងចេះខ្មែរ គាត់មកថតតាំងពីសម័យយើងនៅវៃគ្នាខ្មែរក្រហមនិងលន់ នល់វៃគ្នានោះ ។

ប៊ុនថន : បាទ ។

ជឿន : មកតាំងពីហ្នឹងម៉េះ ចឹងគាត់ចេះខ្មែរច្រើន ។

ប៊ុនថន ៖ តា ប៉ុកហ្នឹង?

ជឿន ៖ ទេ តា ស៊ា ខ្ញុំហៅឡៅ ស៊ា ឡៅ ប៉ុកចឹងទៅ ។

ប៊ុនថន ៖ ឡៅហ្នឹងស្អីគេ?

ជឿន ៖ ឡៅហ្នឹងដូចថាហៅអីចឹងណាស់ ។

ប៊ុនថន ៖ បាទ!ស្គាល់តែបីនាក់ហ្នឹងច្បាស់?

ជឿន ៖ ស្គាល់តែបីនាក់ហ្នឹងហើយមានច្រើនទៀតតែខ្ញុំមិនស្គាល់ច្បាស់មួយប្រធានគេអត់ស្គាល់ទេ គាត់មិនសូវរាក់ទាក់ជាមួយក្មេងៗពួកខ្ញុំនោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គាត់មិនសាកសួរបើតាបីនាក់ហ្នឹងគាត់លេងសើច បើតា ហៃហ្នឹងចូលចិត្តណាស់ជាមួយពួក ខ្ញុំហ្នឹងគៀកកទៅពោធិចិនតុងអីឡើងយន្តហោះអីចឹងទៅ ។

ប៊ុនថន ៖ តែគាត់ចាស់ៗហើយអ្នកមីង?

ជឿន ៖ គាត់ចាស់ៗដែលហើយ កាលហ្នឹងខ្ញុំអាយុត្រឹម២០ឆ្នាំហ្នឹង គាត់អាយុ៤០ជាង៥០អីចឹង ទៅណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គាត់ចំណាស់ៗហើយ ។

ប៊ុនថន ៖ គាត់មកចឹងគាត់និយាយខ្មែរផងចិនផងអ្នកមីង?

ជឿន ៖ បើអ៊ឹស៊ាគាត់និយាយខ្មែរប៉េឡាំៗ បើតា ប៉ុកនិងតា ហៃហ្នឹងគាត់អត់និយាយទេ គ្រាន់តែ ហៅឈ្មោះយើងប៉ុណ្ណឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដូចថាខ្ញុំឈ្មោះជឿនចឹង គាត់ហៅជឿនទៅ តែគាត់និយាយប៉េឡាំៗ ។

ប៊ុនថន ៖ ចឹងមីងមានចេះចិនមួយម៉ាត់ៗដែរ?

ជឿន ៖ អត់ទេ ។

ប៊ុនថន ៖ មីងមិនដែលរៀន?

ជឿន ៖ ចេះតែហូបបាយ ។

ប៊ុនថន ៖ ហូបបាយគេថាយ៉ាងម៉េចទៅ?

ជឿន ៖ ឈឹកហ្វាន់ ។

ប៊ុនថន ៖ ឈឹកហ្វាន់?

ជឿន ៖ ចាស ។

ប៊ុនថន ៖ តែភាសាផ្សេងទៀត?

ជឿន ៖ អត់ចេះ គាត់ប្រាប់តែភាសាហូបបាយហ្នឹងហើយ ។

ប៊ុនថន ៖ ចឹងធ្វើការទំនាក់ទំនងទៅមានអ្នកបកប្រែយ៉ាងម៉េច?

ជឿន ៖ មានអ្នកមកប្រែ នៅកន្លែងហ្នឹងមានអ្នកមកប្រែចិនពីរនាក់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ នារីៗនៅជាមួយខ្ញុំហ្នឹង គេបកប្រែផងជាដាំបាយខ្ញុំផង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ តែខ្ញុំដាំបាយច្រើនជាងគេ ខ្ញុំអត់ជំនាញខាងចេះភាសាអីផង ។

ប៊ុនថន ៖ នារីក្មេងៗដែរ?

ជឿន ៖ ក្មេងៗស្របារៗខ្ញុំហ្នឹង ។

ប៊ុនថន ៖ តែគេកូនចៅចិន?

ជឿន ៖ គេកូនចិនគេបានរៀនចិន ពួកហ្នឹងរៀនបានថ្នាក់ទីប៉ុន្មានទេរៀនចិនមួយហ្នឹងនៅកំពង់ចាមមួយទៀតនៅក្រចេះ ។

ប៊ុនថន ៖ ចេះចិន?

ជឿន ៖ ចាស!ចេះចិន ។

ប៊ុនថន ៖ ចឹងក្រៅពីបកហ្នឹងមួយជួយដាំបាយមីង?

ជឿន ៖ ចាស!ដល់អត់ត្រូវម៉ោងបកប្រែចឹងគាត់មកជួយដាំបាយខ្ញុំជួយធ្វើម្ហូប ។

ប៊ុនថន ៖ ចឹង១០នាក់ថាមកបង្រៀនហ្នឹងមានដូគ្នាទេមីងដូចថាដូរទៅស្រុកចិនអីឬនៅហ្នឹងរហូត?

ជឿន ៖ អត់ដូទេ ដល់ថ្ងៃសៅយន្តហោះចុះចឹងគាត់ចង់ទៅប្រទេសគាត់គាត់ទៅៗដល់នេះគាត់មកវិញហ្នឹង ។

ប៊ុនថន ៖ ចឹងទៅលេង?

ជឿន ៖ ចាស!ដល់នេះគាត់មកវិញ ថ្ងៃសៅយន្តហោះចុះគាត់មកវិញ ។

ប៊ុនថន ៖ មួយអាទិត្យអីចឹង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងដល់ទៅម្តងៗមីងជូនទៅអីចឹង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ជូនឡើងយន្តហោះអី?

ជឿន ៖ ចាស!ជូនឡើងយន្តហោះអីពួកខ្ញុំជាមួយដែរ ។

ប៊ុនថន ៖ ទៅទាំងអស់គ្នា?

ជឿន ៖ ចាស ។

ប៊ុនថន ៖ មួយក្រុមមីងមានគ្នាប៉ុន្មាននាក់មីង?

ជឿន ៖ ពួកខ្ញុំអ្នកដាំបាយមានតែអ្នកបកប្រែមានពីរនាក់ អ្នកដាំបាយហ្នឹងមុនដំបូងខ្ញុំទៅម្នាក់ឯងពីរនាក់ម្នាក់និងដាំឲ្យពួកយុទ្ធជនសម្រាប់ពួកសិក្ខាកាមដែលរៀននោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!តែម្នាក់ទេ ខ្ញុំដាំឲ្យភ្ញៀវតែម្នាក់ឯងទេ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដល់ក្រោយមកទៀតបានគេហៅម្នាក់ទៅទៀតបានពីរនាក់ខ្ញុំ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ពីរនាក់បកប្រែពីរនាក់ដាំបាយ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ទាំងអស់គ្នា៤នាក់ ម្នាក់ហ្នឹងដាំបាយឲ្យយុទ្ធជន ។

ប៊ុនថន ៖ ចឹងតែ៤នាក់ទេស្រី ៗ ?

ជឿន ៖ ចាស!តែ៤នាក់ទេ ។

ប៊ុនថន ៖ ចឹងកាលទៅអ្នកមីងជូនទៅអីចឹង?

ជឿន ៖ ចាស!ដល់ថ្ងៃសៅរ៍យន្តហោះចុះចឹងទៅ ភ្ញៀវចុះមកពីប្រទេសគាត់ខ្លះក៏ទៅចឹងទៅពួកគាត់នាំខ្ញុំទៅ ទៅលេង ។

ប៊ុនថន ៖ ទៅស្គាល់ពោធិចិនតុង?

ជឿន ៖ ចាស!ទៅលេងពោធិចិនតុង ។

ប៊ុនថន ៖ ខស្សប្រាហ៍បានទៅដែលអ្នកមីង?

ជឿន ៖ ឲ្យតែថ្ងៃសៅរ៍ពួកខ្ញុំទៅហើយ ។

ប៊ុនថន ៖ ទៅលេង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងជិះឡានជាមួយគាត់អីចឹង?

ជឿន ៖ ជិះឡានជាមួយគាត់ ។

ប៊ុនថន ៖ ចឹងគាត់មាននាំដើរក្រៅពីពោធិចិនតុងមានទៅកន្លែងផ្សេងទៀត?

ជឿន ៖ អត់មាន បើមាននាំដើរមានតែពួករៀនថតពួកខ្ញុំមិនអាចដើរបានព្រោះនៅធ្វើម្ហូប ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដល់ម៉ោងធ្វើម្ហូបធ្វើម្ហូប ។

ប៊ុនថន ៖ ចឹងអ្នករៀនថតហ្នឹងបានដើរ?

ជឿន ៖ បានដើរថតតាមដូចថាតាមសហករណ៍ណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ តាមទំនប់ការដ្ឋានអីៗផ្សេងៗហ្នឹង គេរៀនចុះជាប់ផ្ទាល់ណាស់ ។

ប៊ុនថន ៖ បាទ!ចុះផ្ទាល់ ។

ជឿន ៖ ដាក់ស្តែង ។

ប៊ុនថន ៖ ចឹងមីងអត់ដែលដើរ?

ជឿន ៖ អត់ ។

ប៊ុនថន ៖ ចឹងពេលទៅ ទៅទាំងអស់គ្នាឬផ្លាស់ប្តូរគ្នាទៅ?

ជឿន ៖ អ្នករៀនថតហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេដាក់វេនគ្នា ដាក់វេនឲ្យចុះថត ។

ប៊ុនថន ៖ ចឹងថតមកមីងមានបានរូបថតអីមើលទេមីង?

ជឿន ៖ អត់ដែលបានមើលទេ គេចុះទៅថតចឹងទៅយកមកកាត់ត ។

ប៊ុនថន ៖ នៅកន្លែងហ្នឹងមានកាត់តទៀត?

ជឿន ៖ ចាស!កាត់តតែម្តង ។

ប៊ុនថន ៖ កាត់តធ្វើអីវិញធ្វើកុនឯកសារឬមួយយ៉ាងម៉េច?

ជឿន ៖ ធ្វើកុនដាក់កុនតែម្តង ។

ប៊ុនថន ៖ ចឹងមិងមានបានមើលដែរ?

ជឿន ៖ ខ្ញុំបានមើលដូចជាគេបញ្ចាំងឯសាកហ្នឹងឃើញដឹងថាការដ្ឋានណាទេ កន្លែងជីកទំនប់ប្រឡាយណាមានវាស្រែមានកន្លែងសហករណ៍យើងដាំកប្បាសអី ។

ប៊ុនថន ៖ ចឹងមានដាំកប្បាសដែរ?

ជឿន ៖ ចាស!ថតដើមកប្បាសដើមអី ។

ប៊ុនថន ៖ គេបញ្ជាំងឲ្យមើលយូរដែលមីង?

ជឿន ៖ មើលមួយកាសែតដែលគេកាត់តបានហ្នឹង ។

ប៊ុនថន ៖ គេបញ្ជាំងនៅកន្លែងមីងតែម្ដង?

ជឿន ៖ បញ្ជាំងនៅកន្លែងហ្នឹងតែម្ដងគេសាក ។

ប៊ុនថន ៖ ចឹងបញ្ជាំងឲ្យអ្នកណា?

ជឿន ៖ ឲ្យអ្នកសិក្ខាកាមដែលរៀនហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!សិក្ខាកាមនិងពួកអ្នកដាំបាយហ្នឹងអត់មានពីណាទៅមើលទេ ។

ប៊ុនថន ៖ ចឹងមើលហើយមីងអត់មានសួរឆ្ងល់ថានៅណា?

ជឿន ៖ អត់ អត់សួរផងអត់បានសួរ ។

ប៊ុនថន ៖ តែមើលទៅដូចជាប្លែកដែលអ្នកមីង?

ជឿន ៖ ប្លែកដើរថតតាមសហករណ៍វាលស្រែអីចឹង ទេសភាពវាល្អចឹងទៅ ។

ប៊ុនថន ៖ ចឹងមីងនៅហ្នឹងបន្ទាប់ពីកន្លែងដាំបាយឲ្យក្មៀវបង្រៀនថតហ្នឹងមីងទៅណាទៀត?

ជឿន ៖ ខ្ញុំមកនៅអគ្គភាពចាស់ខ្ញុំវិញ កន្លែងដំណាក់និរសាហ្នឹងជិតវាំងដដែល ។

ប៊ុនថន ៖ ជិតវាំងដដែល?

ជឿន ៖ ចាស ។

ប៊ុនថន ៖ អត់នៅក្នុងវាំងទៀតទេ?

ជឿន ៖ អត់ទេ ។

ប៊ុនថន ៖ នៅជិតវាំង?

ជឿន ៖ ចាស!នៅជិតវាំងនៅមាត់ទន្លេ ។

ប៊ុនថន ៖ ដំណាក់អីវិញមីង?

ជឿន ៖ គេហៅដំណាក់និរសាដូចជាអ្នកនាំសារមកពីណាមកស្នាក់នៅកន្លែងហ្នឹងសិន ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!ដូចថាមានកំលាំងអគ្គភាពណាឬភូមិភាគណាមកស្នាក់ហ្នឹងសិន មកដល់កន្លែងហ្នឹងគេបែងចែកកំលាំង ។

ប៊ុនថន ៖ បាទ ។

ជឿន :	បែងចែកកំលាំងទៅអគ្គភាពនេះទៅធ្វើការនេះទៅធ្វើការនោះចឹងទៅ ។

ប៊ុនថន :	ចឹងដំណាក់និរសានៅជាប់មាត់ទន្លេតែម្តង?

ជឿន :	ជាអ្នកនាំសារនៅមាត់ទន្លេ ។

ប៊ុនថន :	នៅកន្លែងវត្តដំបូលបន្តិចមានសាលប្រជុំ?

ជឿន :	ឥឡូវមិនដឹងជាហៅស្អីទេត្រង់ហ្នឹង វាថាដូចកោះជ្រោយចង្វារវាហួសមកចេះពួកខ្ញុំនៅនេះ ។

ប៊ុនថន :	បាទ ។

ជឿន :	ទន្លេបួនមុខហួសមកចេះហើយខ្ញុំនៅ ។

ប៊ុនថន :	បាទ ។

ជឿន :	នៅឆ្ងាយពីវត្តខណ្ឌាឡោមប្រហែលជា៥០០ម៉ែត្រហ្នឹង ។

ប៊ុនថន :	តែទល់មុខមាត់ទន្លេហ្នឹងតែម្តង?

ជឿន :	ចាស!មាត់ទន្លេហ្នឹង ។

ប៊ុនថន :	គេហៅដំណាក់និរសា?

ជឿន :	ចាស!កន្លែងហ្នឹងគេហៅដំណាក់និរសាលេខគេដាក់«ក៧» ។

ប៊ុនថន :	«ក៧»?

ជឿន :	ចាស ។

ប៊ុនថន :	មឹងនៅហ្នឹងមានគ្នាច្រើនទេ កន្លែងអ្នកមីងនៅ?

ជឿន :	«ក៧»ហ្នឹងនៅគ្នាច្រើនដែរ ។

ប៊ុនថន :	បាទ ។

ជឿន :	កន្លែងហ្នឹងជាកន្លែងចែកចាយកំលាំង ចែកចាយទាំងផ្លែឈើដែលគេដឹកតាមភូមិភាគយកមកដាក់ត្រង់ហ្នឹងហើយចែកយកទៅឲ្យតាមរោងចក្រ ។

ប៊ុនថន :	បាទ ។

ជឿន :	ចែកឲ្យតាមមន្ទីរពេទ្យ ។

ប៊ុនថន :	បាទ ។

ជឿន :	មានផ្លែឈើមានផ្លែក្រូចអីចឹងពួកខ្ញុំជាអ្នកដឹកចែក ។

ប៊ុនថន :	ចុះនិយាយថាប្រធានខាងផ្នែកហ្នឹង?

ជឿន :	ប្រធានទៅពីហ្នឹងនោះ ។

ប៊ុនថន :	បាទ ។

ជឿន ៖ ហ្នឹងប្រធានដឹកនាំខ្ញុំតាំងពីសម័យសង្គ្រាមដែលស្លាប់នៅសំឡូតហ្នឹង ។

ប៊ុនថន ៖ គាត់ថាជាជនជាតិហ្នឹង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ គាត់ឈ្មោះ...?

ជឿន ៖ គាត់ឈ្មោះ...អីណាទេភ្លេចបាត់ហើយដឹងឈ្មោះពីអីទេ ភ្លេចបាត់ហើយ ភ្លេចឈ្មោះគាត់បាត់ទៅ ។

ប៊ុនថន ៖ បាទ!គាត់គ្រប់គ្រងមិនហ្នឹងមកហ្នឹងគាត់គ្រប់គ្រងទៀត?

ជឿន ៖ ចាស!គ្រប់គ្រងទៀត ។

ប៊ុនថន ៖ មួយកងមីងមានប៉ុន្មាននាក់នៅកន្លែងដំណាក់និរសាហ្នឹង?

ជឿន ៖ គ្នាច្រើនដែលមិនដឹងជាប៉ុន្មាន ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មិនដឹងជាប៉ុន្មាននាក់ទេ ហើយសម្រាប់ដាំបន្លែ ។

ប៊ុនថន ៖ ចឹងដាំបន្លែទៀត?

ជឿន ៖ ចាស!ដាំបន្លែនៅកោះជ្រោយចង្វា ។

ប៊ុនថន ៖ នៅជ្រោយចង្វា?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងជិះទូកទៅដាំទៅ?

ជឿន ៖ ចាស!ជិះទូកទៅដាំ ។

ប៊ុនថន ៖ មិញថាមួយកងមីងមានប៉ុន្មាននាក់ កន្លែងដំណាក់និរសា?

ជឿន ៖ កន្លែងដំណាក់និរសាហ្នឹងខ្ញុំអត់ចាំបានទេ ដូចថាគេរៀបអីហ្នឹងមានបីកង ។

ប៊ុនថន ៖ បាទ!បីកង ។

ជឿន ៖ បើនៅកន្លែងហ្នឹងខ្ញុំអត់ចាំបានទេ ចាំបានតែក្នុងក្រុមខ្ញុំតែម្តង ។

ប៊ុនថន ៖ មួយក្រុមមានប៉ុន្មាននាក់?

ជឿន ៖ មួយក្រុមមាន១២នាក់ នៅពីរក្រុមកន្លែងហ្នឹងស្រីៗ ។

ប៊ុនថន ៖ ចឹងពីរក្រុម២៨នាក់?

ជឿន ៖ ចាស!ហើយប្រុសៗមិនដឹងជាប៉ុន្មានក្រុមទេ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេនៅខាងបើកកាណូត ។

ប៊ុនថន ៖ នៅសុទ្ធតែស្រីៗទាំងអស់ឬលាយគ្នាជាមួយប្រុសៗ?

ជឿន ៖ ប្រុសៗគេនៅផ្ទះផ្សេងតែនៅក្នុងអគ្គភាពហ្នឹងដែរ នៅក្នុងមន្ទីរហ្នឹង ។

ប៊ុនថន ៖ ចឹងដល់មានផ្លែឈើត្រីសាច់អីមីងអ្នកដឹកចែកចាយ?

ជឿន ៖ ចាស!ដឹកចែកចាយ ។

ប៊ុនថន ៖ ដឹកយ៉ាងម៉េចទៅដូចជាមានបញ្ជីរគេមើលថាដឹកទៅដាក់កន្លែងណាៗចឹងអ្នកមីង?

ជឿន ៖ ចាស!ដឹកយកទៅចែកមន្ទីរពេទ្យ ។

ប៊ុនថន ៖ កាលហ្នឹងមានមន្ទីរពេទ្យអីខ្លះមីង?

ជឿន ៖ មន្ទីរ១៧ហ្នឹង ។

ប៊ុនថន ៖ មន្ទីរពេទ្យ១៧មេសា?

ជឿន ៖ ចាស!១៧មេសាហ្នឹងគេហៅមន្ទីរពេទ្យអី...។

ប៊ុនថន ៖ មន្ទីរសូវវៀតហ្នឹង?

ជឿន ៖ ហ្នឹងដឹងពេទ្យសូវវៀតហ្នឹងដឹងរាល់ថ្ងៃ មិនមែនពេទ្យកាលម៉ែតទេ ពេទ្យសូវវៀតហ្នឹងឯង ពេទ្យ១៧នោះ ។

ប៊ុនថន ៖ បាទ!មានពេទ្យអីទៀតអ្នកមីង?

ជឿន ៖ ខ្ញុំចាំបានតែពេទ្យ១៧ ពេទ្យកុមារហ្នឹងមិនដឹងគេហៅពេទ្យអីទេ ពេទ្យអីមិញដែលលោកគ្រូថាហ្នឹង ។

ប៊ុនថន ៖ ពេទ្យកាលម៉ែត?

ជឿន ៖ ចាស!ពេទ្យកាលម៉ែត ដូចជាមិនដែលបានទៅទេ បើដឹកទៅពេទ្យ១៧ទៅ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ហើយឲ្យពួកតាមរោងចក្រហ្នឹង កម្មកររោងចក្រហ្នឹង ។

ប៊ុនថន ៖ ចឹងមីងមានបានដឹកទៅឲ្យអឺៗអីទេអត់មាន?

ជឿន ៖ អត់មានដឹកទេ ដូចថារបបគាត់ផ្សេងយកទៅឲ្យគាត់ផ្សេង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មានគេយកទៅឲ្យគាត់ផ្សេងមានអ្នកនៅហ្នឹង ផ្ញើសម្រាប់គាត់ចឹងទៅដាំស្លឲ្យគាត់ហ្នឹងផ្សេង នៅឆ្ងាយៗពីគ្នា នៅទីក្រុងភ្នំពេញដែលតែនៅឆ្ងាយពីគ្នា ។

ប៊ុនថន ៖ អ្នកមីងនៅយូរដែលអ្នកមីង?

ជឿន : នៅទីក្រុងភ្នំពេញខ្ញុំនៅតាំងពីដាច់ទីក្រុងភ្នំពេញនៅឆ្នាំ៧៥ខ្ញុំនៅរហូតដល់រត់៧៩ហ្នឹង ។

ប៊ុនថន : នៅកន្លែងដំណាក់និរសានោះដល់ដាច់តែម្តងឬផ្លាស់ទៅកន្លែងផ្សេងទៀត?

ជឿន : អត់ទេ ក្រោយមកទៀតខ្ញុំមកនៅកន្លែងបច្ចេកទេសចិន ។

ប៊ុនថន : នៅកន្លែងបច្ចេកទេសចិន?

ជឿន : ចាស!គ្រួសារខ្ញុំមកនៅកន្លែងបច្ចេកទេសចិនហ្នឹងគាត់បើកបរឡានហ្នឹងខ្ញុំមកនៅហ្នឹងដែរ គេយកខ្ញុំមកនៅហ្នឹងដែរ ។

ប៊ុនថន : បាទ ។

ជឿន : ចាស!ខ្ញុំនៅខ្ញុំមិនបានធ្វើអីទេព្រោះអីខ្ញុំមានកូនហើយណាស់ ។

ប៊ុនថន : បាទ ។

ជឿន : ចាស!មិនបានធ្វើអីច្រើនទេ នៅជួយចិតបន្លែជួយហាន់សាច់អីប៉ុណ្ណឹងធ្វើម្ហូបអីមិនបានធ្វើទេកាលហ្នឹង ។

ប៊ុនថន : គ្រួសារអ្នកមីងហ្នឹងមីងរៀបការឆ្នាំណា?

ជឿន : ខ្ញុំរៀបការឆ្នាំ៧៦ ។

ប៊ុនថន : ៧៦?

ជឿន : ចាស ។

ប៊ុនថន : កាលហ្នឹងមីងនៅអង្គភាពណា មីងរៀបការហ្នឹង?

ជឿន : រៀបការហ្នឹងខ្ញុំនៅដំណាក់និរសាហ្នឹងហើយ ។

ប៊ុនថន : ដំណាក់និរសាហ្នឹង?

ជឿន : ហ្នឹងហើយ«ក៧»ហ្នឹង ។

ប៊ុនថន : ចឹង«ក៧»មីងមកនៅហ្នឹងឆ្នាំ៧៦ពេលត្រឡប់មកពី?

ជឿន : អត់ទេ ដាច់៧៥ចូលមកហ្នឹងនៅ«ក៧»ហ្នឹងតែម្តង នៅ«ក៧»ហើយបានខ្ញុំចេញមកដេរស្រោមខ្នើយនៅវាំង កន្លែងវាំងខ្ញុំទៅមកៗកន្លែងហ្នឹងហើយ ។

ប៊ុនថន : បាទ ។

ជឿន : «ក៧»និងកន្លែងវាំងហ្នឹងនៅជិតគ្នា ។

ប៊ុនថន : បាទ ។

ជឿន : ខ្ញុំទៅមកៗខ្ញុំចង់ដេកហ្នឹងជាមួយអ្នកដាំបាយឲ្យអីៗនៅវាំងក៏ខ្ញុំដេកបានតែខ្ញុំមិនដេកខ្ញុំទៅដេក»ក៧»វិញ ។

ប៊ុនថន ៖ ចឹងកាលហ្នឹងមីងរៀបការហើយនៅ?

ជឿន ៖ នៅទេ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មកដល់ឆ្នាំ៧៦ បានរៀបការហើយ គ្រួសារខ្ញុំនៅបើកបរឡាន បើកបរឡានភ្ញៀវទៅគេយកខ្ញុំទៅកន្លែងភ្ញៀវ ។

ប៊ុនថន ៖ ភ្ញៀវចិន?

ជឿន ៖ ភ្ញៀវចិនដែរ ។

ប៊ុនថន ៖ គាត់នៅខាងអគ្គភាពណាវិញ?

ជឿន ៖ ហ្នឹងខាងក្រសួងការបរទេស ។

ប៊ុនថន ៖ ក្រសួងការបរទេស?

ជឿន ៖ ចាស ។

ប៊ុនថន ៖ គ្រួសារមីងនៅហ្នឹងរហូតឬមួយទៅណាទៀត?

ជឿន ៖ គ្រួសារពួកខ្ញុំនៅផ្ទះផ្សេងចឹង គ្រួសារនៅផ្ទះផ្សេងចាំបើកបរដឹកភ្ញៀវទៅតាមខេត្ត ។

ប៊ុនថន ៖ ដឹកទៅយូរថ្ងៃដែលម្តងៗ?

ជឿន ៖ ជួនកាលទៅពីរបីថ្ងៃចឹងទៅកំពង់សោមទៅកំពង់ឆ្នាំង ទៅកែបទៅកំពតអីចឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!ដឹកភ្ញៀវទៅ ភ្ញៀវត្រូវត្រង់ណាចឹងដឹកភ្ញៀវទៅ ។

ប៊ុនថន ៖ ចឹងគាត់មានចេះភាសាចិនអីដែរ?

ជឿន ៖ អត់ទេ មានអ្នកបកប្រែទៅជាមួយ ឡានមួយចឹងមានអ្នកមកប្រែចិនទៅជាមួយអ្នកមកប្រែនៅខាងត្បូងនៅខាងចក្រីខាងស្ទឹខាងខ្មែមហ្នឹងឯងប្រុស ។

ប៊ុនថន ៖ គាត់ចេះចិន?

ជឿន ៖ គាត់ចេះចិន ។

ប៊ុនថន ៖ ប៉ុន្តែគាត់ខ្មែរទេ?

ជឿន ៖ គាត់កូនចិននៅខាងកំពតនោះ អ្នកកំពតមានអ្នកមកប្រែច្រើន ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ កូនចិនច្រើនណាស់អ្នកកំពតនោះ ។

ប៊ុនថន ៖ ចេះមកប្រែចិន?

ជឿន ៖ ចាស ។

ប៊ុនថន ៖ នៅជាមួយគ្រួសារអ្នកមីងហ្នឹង កាលហ្នឹងមីងមានទម្ងន់កូនទី១?

ជឿន ៖ កាលមុនខ្ញុំនៅកន្លែងបើកបរឡានខ្ញុំអត់ទាន់ទៅកន្លែងជូនភ្ញៀវហ្នឹងខ្ញុំនៅខាង«ក១២»កន្លែងបើកបរតែមានអគ្គភាពបើកបរផ្សេងចឹង ដូចថាខាងភ្ញៀវគេត្រូវការអ្នកទទួលខុសត្រូវមន្ទីរសម្រាប់ដឹកភ្ញៀវអីចឹងណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេត្រូវការឡានចឹងមកសុំកន្លែង«ក១២»ចឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ កាលមុនខ្ញុំនៅត្រង់ហ្នឹងដំបូងនោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!ដែលបានគ្រួសារហើយដល់ខ្ញុំមានកូនពីរបានខ្ញុំទៅនៅកន្លែងក្រសួងការបរទេសតែម្ដងកាលហ្នឹង ។

ប៊ុនថន ៖ ទៅនៅជាមួយគ្រួសារអ្នកមីង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចុះគាត់នៅខាងបើកឡានដដែល?

ជឿន ៖ ចាស!គាត់នៅខាងបើកឡានដដែល កាលមុនមន្ទីរបើកបរហ្នឹងនៅជាមួយគ្នាដល់គេសុំកំលាំងទៅដឹកភ្ញៀវទៅកុំឲ្យពិបាកសុំចុះសុំឡើងទៅនៅប្រចាំហ្នឹងតែម្ដង ។

ប៊ុនថន ៖ គេយកទៅដាច់តែម្ដង?

ជឿន ៖ ចាស!គេយកដាច់ចឹងតែម្ដង ។

ប៊ុនថន ៖ ចឹងមីងនៅជាមួយគាត់រហូតមកឬមួយយ៉ាងម៉េច?

ជឿន ៖ រហូតមកដល់រត់៧៩ហ្នឹង ។

ប៊ុនថន ៖ នៅក្រសួងការបរទេសហ្នឹង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងមីងមានធ្វើអីដែលនៅហ្នឹង?

ជឿន ៖ នៅក្រសួងការបរទេសហ្នឹងអត់មានធ្វើអីផង យើងមានកូនចឹងគ្រាន់តែជួយចិតបន្លែពួកនារីៗហ្នឹង នារីៗគេនៅលីងចឹងគេនៅដាំបាយធ្វើម្ហូបឲ្យភ្ញៀវ ។

ប៊ុនថន ៖ បាទ!ចឹងកាលហ្នឹងមីងមានដឹងថាក្រសួងការបរទេសអ៊ីណាជាអ្នកគ្រប់គ្រងទេ?

ជឿន : កាលនោះដឹងអីណាទេ ខ្ញុំមិនសូវដឹងដែរ ។

ប៊ុនថន : បាទ ។

ជឿន : ដឹងអីមួយណាអត់ដឹងច្បាស់ គ្នាគាត់ឡើងប៉ុន្មាននាក់ដឹងអីមួយណាអ្នកគ្រប់គ្រងក្រសួងការបរទេសហ្នឹង ។

ប៊ុនថន : ចឹងគាត់មានដែលចុះមកមើលមីងដាំបាយទេ?

ជឿន : អត់ទេ ។

ប៊ុនថន : អត់ដែលទេ?

ជឿន : ចាស ។

ប៊ុនថន : ចឹងមីងមានស្គាល់ពូ គង់នៅហ្នឹងដែរ?

ជឿន : តា គង់ហ្នឹង ។

ប៊ុនថន : បាទ!គាត់ធ្វើការនៅហ្នឹងដែលមីង?

ជឿន : កាលខ្ញុំនៅរៀបចំផ្ទះជួបអ៊ីគង់ ។

ប៊ុនថន : ចឹងជួប?

ជឿន : ចាស!នៅជាមួយអ៊ីគង់ហ្នឹង អ៊ី គង់ តា ឆន ពួកខាងបញ្ញាជន ។

ប៊ុនថន : បាទ ។

ជឿន : តា មុត តាអីខ្លះទេភ្លេចអស់ហើយច្រើនដែរ ពួកបញ្ញាជនខ្ញុំនៅជាមួយគាត់ផ្ទាល់តែម្តង ។

ប៊ុនថន : ចឹងមីងនៅជាមួយគាត់?

ជឿន : ចាស!គាត់នាំរៀបចំឈ្មោះ បង ផាត ឈ្មោះ បង សន ឥឡូវបង សនហ្នឹងគាត់នៅអីណាឥឡូវហ្នឹងដល់រត់៧៩ចឹងបែកបាក់គ្នាអស់ហើយពួកគាត់ហ្នឹងឯងអ្នកនាំរៀបផ្ទះ ។

ប៊ុនថន : រៀបផ្ទះ?

ជឿន : ចាស!មានពួកគាត់ហ្នឹងហើយអ្នករៀបផ្ទះហ្នឹង រៀបផ្ទះធ្វើយ៉ាងម៉េចដាក់ធ្វើយ៉ាងម៉េចហ្នឹងកាលហ្នឹង ។

ប៊ុនថន : រៀបផ្ទះនៅណា?

ជឿន : ផ្ទះបោសសម្អាតដូចភ្ញៀវមកស្នាក់នោះ ។

ប៊ុនថន : ចឹងក្រោយមកបានមីងស្គាល់គាត់?

ជឿន : ចាស ។

ប៊ុនថន : មកនៅក្រសួងការបរទេសហើយ?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ពីមុនហ្នឹងគាត់នាំរៀបភ្ញៀវ?

ជឿន ៖ ចាស!គាត់អ្នកនាំរៀបហ្នឹង ។

ប៊ុនថន ៖ ចឹងក្រោយមកមីងមានស្គាល់គាត់ទេ នៅពេលដែលរត់មកនៅនេះ?

ជឿន ៖ មកនៅនេះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ខ្ញុំស្គាល់តែគាត់មិនស្គាល់ខ្ញុំទេ ។

ប៊ុនថន ៖ មីងនៅក្រសួងការបរទេសដល់៧៩ពេលវៀតណាមចូលហ្នឹងមីងរត់ទៅណាវិញមីង?

ជឿន ៖ ពួកខ្ញុំរត់មកពួកជិះរថភ្លើងមកខាងបាត់ដំបងហ្នឹងហើយ ។

ប៊ុនថន ៖ រត់មកបាត់ដំបង?

ជឿន ៖ ចាស!រត់មកហ្នឹងតែម្តងរត់មកនៅហ្នឹងឯង ។

ប៊ុនថន ៖ នៅម៉ាឡៃហ្នឹងតែម្តងមីង?

ជឿន ៖ ចាស!តែមុនមកនៅនេះខ្ញុំច្រើនកន្លែងណាស់រត់ រត់ចង់ងាប់ចង់រស់រត់តាមផ្លូវ៥០២ហ្នឹង មក មកនៅនេះហើយមកនៅបឹងបេង នៅបឹងបេងហើយខ្ញុំចេញពីបឹងបេងហ្នឹងរត់ទៅនៅ ប៉ៃលិនវិញ ដល់គេថាយួនមកពីស្ពានថ្មហើយរត់ពីប៉ៃលិនមកនៅសាលាក្រៅ គេថាយួនជិត មកដល់នេះហើយរត់ពីសាលាក្រៅមក មកនៅជិតតា គង់នេះស្អីត្រង់ណាទេ កន្លែងទំនប់ ហ្នឹងនោះ គេហៅអូរកំពូលអូរសន្តាយ ។

ប៊ុនថន ៖ អូរកំពូលអូរសន្តាយ?

ជឿន ៖ ចាស!នៅតាមសហករណ៍ គេពួកខ្ញុំហ្នឹងទៅតាមសហករណ៍ គេថាយួនមកពីខាងព្រៃខ្ពស់ ហើយពួកខ្ញុំហ្នឹងរត់ចេញពីហ្នឹងមកទៀត រត់មកបានមកនៅណាទេ គេហៅអូរដាអីណាទៅ កំរៀងអីបានរត់ចូលបឹងឆ្នាំង ចេញពីបឹងឆ្នាំងបានឆ្ងាយមកនេះវិញ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មកដល់ហ្នឹងយូរ នៅហ្នឹងរត់ឡើងប៉ុន្មានសា នៅនេះមួយរយៈហើយពួកខ្ញុំគេដឹកទៅខាងដង រែក ។

ប៊ុនថន ៖ ភ្នំដងរែក?

ជឿន ៖ ចាស!គេថាដងរែកហ្នឹងដីទូលាយស្រួលរត់យួនអត់ដេញ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ច្រើនកន្លែងណាស់ បានមកពីដងវែកវិញបានមកនៅនេះបានយូរនៅនេះបានមួយរយៈគេថាយួនដេញមកទៀតនាំគ្នារត់ទៅប៉ៃលិននៅភ្នំខៀវ ។

ប៊ុនថន ៖ នៅភ្នំខៀវ?

ជឿន ៖ ចាស!មិនបានចូលក្នុងប៉ៃលិនទេនៅក្នុងព្រៃទេណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចេញពីទៅនៅនោះដល់ថាអន្តភាពត្រូវប្រមូលផ្តុំចេញពីហ្នឹងមកវិញបានទៅនៅជំរំហ្នឹងអីគាត់ដួល ។

ប៊ុនថន ៖ បាទ!ដួលនៅណា?

ជឿន ៖ កន្លែងហ្នឹងគេហៅស្ពីទេ ជិតវត្តត្រង់ណាជិតស្រះកែវដែរ ។

ប៊ុនថន ៖ ខ្ញុំមិនសូវដឹងដែលមីង ។

ជឿន ៖ ចឹងទៅនៅហ្នឹងឡើងប៉ុន្មានឆ្នាំដល់ឆ្នាំ៩០បានមកនៅនេះនៅរហូតទាល់តែរាល់ថ្ងៃនេះ ។

ប៊ុនថន ៖ ចឹង៩០បានមកនៅហ្នឹង?

ជឿន ៖ ចាស!ចេញពីនេះទៅតាំងពីឆ្នាំ៨៥ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ឆ្នាំ៨៥ខ្ញុំកំពង់តែពពោះកូនអាមួយនេះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ វាកើតឆ្នាំ៨៥ហ្នឹងទៅកើតអីខាងប៉ៃលិនហ្នឹងនៅភ្នំខៀវ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ បានរត់ទៅនៅជំរំដីថៃហ្នឹងបានចេញពីជំរំដីថៃបានយើងមកនៅហ្នឹងរាល់ថ្ងៃ ។

ប៊ុនថន ៖ ចឹងសួរមីងថាកាលរត់៧៩ហ្នឹងមកដល់ម៉ាឡៃហ្នឹងតែម្តង?

ជឿន ៖ មកនៅហ្នឹងតែនៅច្រើនកន្លែងណាស់ ចេញមកនៅបឹងបេងចេញពីបឹងបេងទៅបានគេថានៅនេះពិបាករត់លូនណាស់ មិនឮខ្ញុំថាទៅនៅប៉ៃលិនទៅនៅក្រុងប៉ៃលិនតែម្តង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ទៅនៅក្រុងប៉ៃលិនគេថាយួនមកហើយៗពួកខ្ញុំហ្នឹងស្ពាយកូនកាលនោះ កាលនោះកូនខ្ញុំតែពីរនាក់ទេ ក៏ស្ពាយកូនមកទៀតមកដល់សាលាក្រៅ ។

ប៊ុនថន ៖ បាទ ។

ជឿន : គេថាមកសាលាក្រោយយួនមកទៀតហើយ ក៏ខ្ញុំរត់ចេញពីសាលាក្រោមកទៀតបានមកនៅអីណាទេ ជិតអូរដាហ្នឹង ។

ប៊ុនថន : បាទ ។

ជឿន : គេហៅស្អីទេ រត់មកនៅហ្នឹងបានប្រហែលជាប៉ុន្មានខែទេ កាលនោះគេថារកវំសាយពួកខ្ញុំចុះឈ្មោះចង់ទៅស្រុកទៅភូមិវិញ ។

ប៊ុនថន : បាទ ។

ជឿន : ដល់តា ហុងគាត់ថាទៅម៉េច ទៅយ៉ាងម៉េចឯងមានស្បៀងអង្ករណាទៅទំរាំទៅដល់ភូមិអីមិនស្លាប់តាមផ្លូវហើយ គាត់ថាចឹង ។

ប៊ុនថន : បាទ ។

ជឿន : គាត់ថាអត់ឲ្យទៅទេ គាត់ថាចឹងគាត់សុខចិត្តទាក់ទងអង្ករស្បៀងអីមកចិញ្ចឹមពួកខ្ញុំហ្នឹងឯង ។

ប៊ុនថន : បាទ ។

ជឿន : ដល់អត់បានទៅដល់ក្រោយមកទៀត ចេញពីហ្នឹងមកបានយកទៅនៅតាមសហករណ៍ ។

ប៊ុនថន : បាទ ។

ជឿន : តាមសហករណ៍ហ្នឹងនៅអូរសន្តាយហ្នឹងឯង ដល់ហើយគេថាយួនបុកមកពីព្រៃខ្ពស់ហើយ ព្រៃខ្ពស់ហ្នឹងដឹងគេហៅអីត្រង់ណាទេ ខ្ញុំអត់ស្គាល់ដែរ ក៏នាំគ្នាចេញពីអូរសន្តាយហ្នឹងទៅតាមសហករណ៍ហ្នឹងទៅតាមប្រជាជនខ្ញុំពកូនពីរហ្នឹងដាក់រទេះប្រជាជនផងពផងអីផងដល់រត់មកជួបអង្គភាពខ្ញុំតាមអង្គភាពខ្ញុំវិញ ។

ប៊ុនថន : បាទ ។

ជឿន : ចាស!ស្គាល់អង្គភាពខ្ញុំវិញ ខ្ញុំមកតាមអង្គភាពខ្ញុំវិញបានរត់មកនៅត្រង់ណាទៀតទេ ខ្ញុំវង្វេងច្រើនណាស់កាលហ្នឹង ត្រឡប់ត្រឡិន ។

ប៊ុនថន : មនុស្សច្រើនទេកាលហ្នឹងកាលរត់ហ្នឹង?

ជឿន : ចាស!ហើយបានគេថាទៅនៅគ្រាង ។

ប៊ុនថន : បាទ ។

ជឿន : ដល់ហើយចេញពីគ្រាងគេថាមកនៅនេះពិបាកណាស់ កន្លែងនេះដំបូងគេហៅតំបន់១០២ គេហៅភូមិប្រយុទ្ធ ។

ប៊ុនថន : នៅណានៅម៉ាខ្សែនេះ?

ជឿន : នៅហ្នឹងដំបូងសុទ្ធតែព្រៃទាំងអស់ ។

ប៊ុនថន ៖ តំបន់១០២?

ជឿន ៖ ចាស! គេហៅតំបន់១០២ នៅហ្នឹងទៅបានប៉ុន្មានទេយួនបុកមក យួនបុកមកពួកខ្ញុំរត់ចេញពីនេះទៅទៀត ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចេញពីនេះទៅទៀតខ្ញុំចេញទៅនៅដងរែក ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដល់ទៅនៅដងរែកមិនដឹងជាប៉ុន្មានខែខ្ញុំអត់ដឹងដែរ គេថាប្រមូលផ្ដុំអន្តោភាពទៅមកពីដងរែកវិញមកនៅនេះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មកនៅនេះ គេថាយួនដេញទៀតបានពួកខ្ញុំរត់ឆ្ងាយទៅភ្នំខៀវ ទៅភ្នំខៀវខ្ញុំពពោះកូនខ្ញុំអានេះឯង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ បានទៅនៅជំរំ៨៥ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ជំរំ៨៥ហ្នឹងនៅជិតវត្តត្រង់ណាហ្នឹង នៅដីថៃនោះណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស! នៅដីថៃចេញពីហ្នឹងមកបានមកនៅហ្នឹងរហូតដល់រាល់ថ្ងៃហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មកនៅនេះខ្ញុំមកនៅ៩០គត់ឆ្នាំ៩០គត់ ។

ប៊ុនថន ៖ ចឹងសួរមីងថាដំបូងនៅម៉ាឡៃហ្នឹងអត់មានមនុស្សនៅទេមីង កាលរត់មកដំបូងនៅបឹងបេង?

ជឿន ៖ អត់មានទេ មានតែអ្នកមកហ្នឹងឯង ។

ប៊ុនថន ៖ ចឹងមានតែអ្នកមកទេ?

ជឿន ៖ ចាស! ។

ប៊ុនថន ៖ សុទ្ធតែព្រៃទាំងអស់មីង?

ជឿន ៖ ចាស! សុទ្ធតែព្រៃទាំងមកដាច់បាយដាច់ទឹកស្លាប់ច្រើនណាស់ ។

ប៊ុនថន ៖ ស្លាប់ដោយសារអីមីង?

ជឿន ៖ ស្លាប់ដោយសារអត់បាយតែម្ដង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ខ្ញុំអីស៊ើរស្លាប់ស៊ើររស់អត់បាយផងខ្វះដេកស្លាប់ ស្លាប់ហើយកូននៅចៅក៏មានដែរ ។

ប៊ុនថន ៖ បាទ!អ្នកដែលរត់មកហ្នឹងមីង?

ជឿន ៖ ចាស!អ្នករត់មកស្លាប់ច្រើនណាស់ ស្លាប់ដោយអត់បាយហ្នឹងតែម្តង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ទំរាំតា១គាត់ទាក់ទងថៃបានទិញអង្ករទិញអី ។

ប៊ុនថន ៖ បឹងបេងហ្នឹងដីបូងមីងមកដល់ហ្នឹងគេអត់ហៅបឹងបេងទេ?

ជឿន ៖ គេហៅបឹងបេងហ្នឹងហើយ ។

ប៊ុនថន ៖ ហៅបឹងបេងតែម្តង?

ជឿន ៖ ចាស!កន្លែងហ្នឹងមានស្រះគេកាយមានស្រះចឹងឯងចឹងបានជាគេហៅបឹងបេង១ ។

ប៊ុនថន ៖ បាទ!ច្រើនទេមីងមកដីបូង?

ជឿន ៖ ច្រើនណាស់ប្រជាជនឡើងភ្នកទឹកភ្នកដីច្រើនតែម្តង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!មិនអាចរៀបរាប់បានទេ ច្រើនតែម្តងប្រជាជន ។

ប៊ុនថន ៖ ហើយមានផ្លូវមានអីទេ?

ជឿន ៖ មានផ្លូវ ផ្លូវ៥០២កាលមុនឥឡូវហ្នឹងស៊ីម៉ាក់កំពង់តែរាវ ។

ប៊ុនថន ៖ ផ្លូវណាផ្លូវរាល់ថ្ងៃហ្នឹងមីង?

ជឿន ៖ តែផ្លូវលំណាស់ មិនមែនផ្លូវនេះទេ ផ្លូវអីនោះទៀតឆ្ងាយអីចំការនោះឥឡូវគេធ្វើចំការធ្វើអីហើយ ។

ប៊ុនថន ៖ គេហៅផ្លូវ៥០២?

ជឿន ៖ ផ្លូវ៥០២ ផ្លូវចាស់ពីដើមមកផ្លូវអាចបើកឡានបាន ឡានបរព្រៃណាស់ ។

ប៊ុនថន ៖ បាទ!ចង់សួរដីបូងនៅម៉ាឡៃហ្នឹងនៅភូមិឃុំស្រុកអីវិញមីង?

ជឿន ៖ កាលនោះអត់មានឈ្មោះស្រុកភូមិ ។

ប៊ុនថន ៖ អត់មានឈ្មោះម៉ាឡៃទេ?

ជឿន ៖ អត់មានទេ ។

ប៊ុនថន ៖ ប៉ុន្តែកន្លែងហ្នឹងនៅក្នុងស្រុកអីវិញ?

ជឿន ៖ ឥឡូវនេះ ។

ប៊ុនថន ៖ អត់ទេ ពីមុនមក?

ជឿន ៖ អត់មានស្រុកទេ ដាក់ម៉ាឡៃហ្នឹងមានឈ្មោះភ្នំម៉ាឡៃ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ម៉ាជួរភ្នំហ្នឹងគេហៅភ្នំម៉ាឡៃដល់ចឹងទៅគេដាក់ស្រុកម៉ាឡៃ ។

ប៊ុនថន ៖ ចឹងកាលពីជំបូងមក?

ជឿន ៖ ពូជំបូងអត់មានមិនដឹងជាគេហៅស្អី ។

ប៊ុនថន ៖ អត់ដឹងហៅអី?

ជឿន ៖ នាំគ្នាហៅភូមិប្រយុទ្ធៗតំបន់១០២ប៉ុណ្ណឹងឯង ។

ប៊ុនថន ៖ ភូមិប្រយុទ្ធតំបន់១០២?

ជឿន ៖ ចាស!អត់ដឹងថាស្រុកអីទេ ។

ប៊ុនថន ៖ នៅក្នុងភូមិភាគអីមីង?

ជឿន ៖ មិនដឹងជាភូមិភាគអីទេ ។

ប៊ុនថន ៖ ភូមិភាគពាយ័ព្យឬមួយយ៉ាងម៉េច?

ជឿន ៖ ភូមិភាគពាយ័ព្យ ។

ប៊ុនថន ៖ តំបន់១០២?

ជឿន ៖ ចាស!កាលនោះបាត់ដំបងនិងបន្ទាយមានជ័យមិនទាន់បែងចែកគ្នាណា ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!នៅខេត្តបាត់ដំបងនៅឡើយហ្នឹង ចឹងនៅក្នុងខេត្តបាត់ដំបងហ្នឹងហើយ ។

ប៊ុនថន ៖ តែមីងមិនដឹងថានៅក្នុងស្រុកអីទេ?

ជឿន ៖ អត់ដឹងថានៅក្នុងស្រុកអីចុះសុទ្ធតែព្រៃមានតែប្រជាពលរត់មកហ្នឹង ។

ប៊ុនថន ៖ កាលមកដំបូងអត់មានមីនទេ កាលរត់មកកាលចូលដំបូង?

ជឿន ៖ កាលដំបូងអត់ដឹងមីន ។

ប៊ុនថន ៖ តែអត់មានគ្រាប់មីនទេ?

ជឿន ៖ អត់មានគ្រាប់មីនទេ ចូលមកដំបូងអត់មានគ្រាប់មីនអីទេ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដល់ពួកខ្ញុំរត់ចេញពីនេះបានយួនមកធ្វើខ្សែមីនតាមនេះ សុទ្ធតែរបងលួស ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ តាមមាត់អូរតាមអីនេះ ពួកខ្ញុំមកនៅមយយសារទៀតហ្នឹងរាប់និងយួនដាក់មិនស្មើរ ។

ប៊ុនថន ៖ ដាន់មីន?

ជឿន ៖ ដាន់មីនមានស្មាច់មានអាក្បាលបីមានមីនក្តាមានមីនស្នូពោតមានអីសព្វ ។

ប៊ុនថន ៖ ហ្នឹងខាងណាដាក់ហ្នឹង?

ជឿន ៖ មិនដឹងខាងណាដាក់ទេ តែខ្ញុំមកវិញឃើញមីនដាក់ចឹងតែម្តងនៅដំបូងរត់មកសុទ្ធតែព្រៃអត់មានមីនទេ ។

ប៊ុនថន ៖ បាទ! ប្រហែលជាឆ្នាំប៉ុន្មាន?

ជឿន ៖ ដែលខ្ញុំរត់មក៧៩នោះ ។

ប៊ុនថន ៖ កាលមីងចូលមកវិញ?

ជឿន ៖ ចូលមកវិញឆ្នាំ៩០ដែលចូលមកវិញមកនៅដល់រាល់ថ្ងៃចូលមកឆ្នាំ៩០ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចូលមកមីនតែម្តងតាមនេះអី នៅម៉ាជិនារខាងក្រោយផ្ទះនោះអីសុទ្ធតែមីនទាំងអស់ ។

ប៊ុនថន ៖ មុនមីងចូលមកហ្នឹងមានគេនៅរួចហើយ?

ជឿន ៖ អត់មានទេ ។

ប៊ុនថន ៖ និយាយថាអ្នកភូមិមកនៅហ្នឹង?

ជឿន ៖ អត់ទេ មានតែពួកខ្ញុំហ្នឹងហើយ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដឹកឡានមកពីដីថៃមកនាំគ្នានៅអត់មានប្រជាជនណានៅទេ ។

ប៊ុនថន ៖ ចឹងមានអ្នក៧៩គាត់អត់ទៅណាគាត់នៅហ្នឹងរហូត?

ជឿន ៖ អត់នាំគ្នារត់ចេញដូចគ្នា ។

ប៊ុនថន ៖ រត់ចេញដូចគ្នា?

ជឿន ៖ ចាស!អ្នកនៅនេះរត់ចេញដូចគ្នា ។

ប៊ុនថន ៖ មីងនៅថៃនៅជំរំ?

ជឿន ៖ គេហៅជំរំ៨៥ ។

ប៊ុនថន ៖ ជំរំ៨៥ ?

ជឿន ៖ ចាស!កាលនាំគ្នារត់ទៅជំរំ៨៥ក៏នាំគ្នាហៅថាជំរំ៨៥ ។

ប៊ុនថន ៖ ទៅនៅប្រហែលជាច្រើននាក់ដែលកាលទៅនៅហ្នឹង?

ជឿន ៖ ច្រើនៗនាក់ណាស់ ។

ប៊ុនថន ៖ ប្រហែលជាប៉ុន្មាននាក់?

ជឿន ៖ នៅតែមីងៗទេ ឯយុទ្ធជនកងទ័ពចេញមកនេះទាំងអស់នៅតែមីងៗទេ ។

ប៊ុនថន ៖ បាទ!មីងថានៅអង្គភាពហ្នឹងអង្គភាពអីវិញមីង?

ជឿន ៖ កាលក្រោយមកហ្នឹងនៅដីថៃដឹងគេហៅអង្គភាពអីទេ នៅតាមអង្គភាពដឹងអង្គភាពអីខ្ញុំអត់ដឹងដែរ ចេញពីក្រសួងការបរទេសអត់មានទេ ។

ប៊ុនថន ៖ ចឹងមីងអត់មានចូលជាអង្គភាពដឹកជញ្ជូនអីអត់មានទេ?

ជឿន ៖ អត់ទេ ព្រោះមានកូនហើយ ខ្ញុំមានគ្រួសារមានកូនខ្ញុំមានកូនឡើងពីរបីនាក់ហើយ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មិនអាចទៅដឹកជញ្ជូនបានទេ ដឹកជញ្ជូនបានតែនារីៗ ។

ប៊ុនថន ៖ ចឹងមីងមកនៅឆ្នាំ៩០ហ្នឹងមីងមកចាប់ដីចាប់អីនៅហ្នឹងតែម្តង?

ជឿន ៖ ចាស!ចាប់ត្រង់ហ្នឹង ។

ប៊ុនថន ៖ ចាប់បានកន្លែងហ្នឹងតែម្តង?

ជឿន ៖ ចាស!ដូចថាមេគេនាំមកដូចថាមេអង្គភាពហ្នឹងណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេនាំមកថាឯងនៅត្រង់នេះ អកផ្សេងនៅត្រង់នោះយើងគ្រួសៗនៅអត់ហ៊ានដើរទេខ្លាចមីននោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ យកចបជីកចូកជីចូកខ្លាចប៉ះមីនខ្លាចអីនោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ មកនៅចែកគ្នានៅចឹងៗទៅជាប់ៗគ្នា ។

ប៊ុនថន ៖ ពីណាចាប់បានប៉ុន្មានគ្រាយបានប៉ុន្មានយកប៉ុណ្ណឹងទៅ?

ជឿន ៖ អ្នកណាគ្រួសបានច្រើនដាងគេហ៊ានទៅបានច្រើនទៅ អ្នកណាខ្លាចបានតូចទៅ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ខ្លះមិនហ៊ាននៅទៀត ចាប់ហើយមិនហ៊ាននៅខ្លាចមីន ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចុះពូមើលម្នាក់នៅក្រោយខ្ញុំនេះដីគាត់អីនោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចំខ្មែរមិនគាត់អត់ហ៊ានទៅ អត់ហ៊ានឲ្យគេទៅដល់គេគេចូកគេអីអត់មានមីនចឹងទៅដល់គេទៅ បាត់គេលក់ទៅដីហ្នឹង គាត់អត់មានកន្លែងនៅក្រោយខ្ញុំបន្តិចហ្នឹង ។

ប៊ុនថន ៖ ចឹងដីចំការគ្រួសក្រោយខ្លួនឯង?

ជឿន ៖ ដីចំការកាត់គ្រួសក្រោយខ្លួនឯង ចំការក៏មីន ។

ប៊ុនថន ៖ ចឹងមីងមានគ្រួសបានចំការបានអីទេ?

ជឿន ៖ បានដីចំការ១០រ៉ៃ ។

ប៊ុនថន ៖ ១០រ៉ៃច្រើន?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ១០មានប៉ុន្មានហិចតា?

ជឿន ៖ ១០មិនបានពីរហិចតាផងហ្នឹងបានមួយហិចតាជាង ។

ប៊ុនថន ៖ ចឹងគ្រួសារអ្នកមីងនៅរាល់ថ្ងៃហ្នឹង?

ជឿន ៖ នៅរាល់ថ្ងៃធ្វើប៉ូសីលនៅ៩៣ ។

ប៊ុនថន ៖ នៅ៩៣?

ជឿន ៖ ចាស ។

ប៊ុនថន ៖ អូ!គាត់ប៉ូលីស?

ជឿន ៖ ចាស ។

ប៊ុនថន ៖ គាត់មកពីហ្នឹងគាត់កងទ័ព?

ជឿន ៖ កាលពីមុនគាត់កងដឹកជញ្ជូន ។

ប៊ុនថន ៖ កងដឹកជញ្ជូន?

ជឿន ៖ ចាស!ដឹកជញ្ជូនខោអាវឬក៏ក្រណាត់គេចែកឲ្យប្រជាជនចឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចែកប្រជាជនអីក្នុង១កាលហ្នឹងពួកខ្ញុំនៅជំរំដីថៃ ។

ប៊ុនថន ៖ គាត់ធ្វើប៉ូលីសក្រោយពេលណាអ្នកមីង?

ជឿន ៖ ដល់មកនៅនេះ គេរំសាយកងទ័ពនោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេរំសាយកងទ័ពទៅខ្លះក៏ឈប់ធ្វើទាហានចិនទៅខ្លះធ្វើប៉ូលីសដូចថាគេចងក្រងមានអង្គភាពប៉ូលីសចិនទៅ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេមានការរៀបចំរៀបរយចិនទៅណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ គេមានប៉ូលីសមានតម្រួតអីចិនទៅគាត់នៅខាងប៉ូលីស ប៉ូលីសព្រំដែន ។

ប៊ុនថន ៖ បាទ!កាលរំសាយកងទ័ពឆ្នាំណា?

ជឿន ៖ ឆ្នាំ៩០ប៉ុន្មានទេខ្ញុំភ្លេច អត់សួរចាមដែរ ។

ប៊ុនថន ៖ អត់សួរចាំដែរ?

ជឿន ៖ ចាស!គេកាត់រំសាយ ។

ប៊ុនថន ៖ មុនសមាហរណ៍កម្មឬក្រោយ?

ជឿន ៖ ដឹងក្រោយឬមុនទេ ភ្លេចហើយ ។

ប៊ុនថន ៖ ក្រោយសមាហរណ៍កម្មឆ្នាំ៩៦?

ជឿន ៖ សមាហរណ៍កម្មហ្នឹងហើយគេរំសាយកងទ័ពនោះ ។

ប៊ុនថន ៖ បាទ!ចូលទៅហ្នឹង?

ជឿន ៖ ចាស ។

ប៊ុនថន ៖ ចឹងចង់សួរមីងមួយដូចថាមុនសមាហរណ៍កម្មនិងក្រោយសមាហរណ៍កម្មមីងគិតថាខុសប្លែកគ្នាយ៉ាងម៉េចដែរ និយាយរឿងជីវភាពនិងការរស់នៅគិតថាស្រួលជាងឬពិបាកជាងឬក៏យ៉ាងម៉េចដែរមីង?

ជឿន ៖ បើប្រៀបធៀបនៅកាលនោះយើងរត់លូត ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដូចថាវាមានសង្រ្គាមអីចឹងណាស់ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ វាប្លែកវាផ្សេងវាមិនដូចរាល់ថ្ងៃ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ រាល់ថ្ងៃបើនិយាយពីការយ៉ាប់យឺនវាយ៉ាប់យឺននៅតែយ៉ាប់យឺនចឹង ព្រោះយើងអ្នកក្រ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ យើងខ្លះសព្វខ្លះគ្រប់ចឹងមានតែដីធ្វើតែអត់ដើមទុនធ្វើ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ យើងអត់ដើមទុនធ្វើវានៅតែលំបាកចឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចឹងយើងចងការប្រាក់គេមកធ្វើផលចំណេញហ្នឹងអាហ្នឹងការគេ នៅតែពិបាកដូចតែគ្នា ។

ប៊ុនថន ៖ ចឹងគិតថាយ៉ាងម៉េចដែរ ពិបាកជាងមុនឬក៏ស្រួលជាងមុន?

ជឿន ៖ រឿងពិបាករស់លូនហ្នឹងវាពិបាកមែនហ្នឹងឯង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ដល់ឥឡូវស្រួលម៉្យាងយើងមានសិទ្ធដើរហើរ ។

ប៊ុនថន ៖ វាអត់មានសង្គ្រាម?

ជឿន ៖ ចាស! វាអត់សង្គ្រាម ។

ប៊ុនថន ៖ ចឹងចង់សួរមីងមួយទៀតដូចជានៅក្នុងសម័យបដិវត្តន៍មីងធ្លាប់ដូចថាជួយអ្នកផ្សេងដូចថាជួយឲ្យជាអាហារជួយស្អីផ្សេងៗ ដូចថាធ្លាប់ជួយឆ្នកខ្លះខាតប្រជាជនអីមីង?

ជឿន ៖ កាលសម័យបដិវត្តន៍ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ រឿងជួយគេខ្ញុំមិនសូវបានជួយទេ ដូចថាយើងនៅតាមអង្គភាពចឹង ។

ប៊ុនថន ៖ អត់បានទៅជួបប្រជាជន?

ជឿន ៖ អត់បានទៅចូលជិតស្និតជាមួយប្រជាជន ដូចថាអ្នកធ្វើការមូលដ្ឋានគេធ្វើការជាមួយមូលដ្ឋានផ្សេង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ អ្នកធ្វើការដូចថានៅក្នុងកងទ័ពវាផ្សេង បែងចែកគ្នាមិនអាចទៅសំណេះសំណាលជាមួយប្រជាជនទេ ។

ប៊ុនថន ៖ ចឹងមកដល់សព្វថ្ងៃហ្នឹងមីងមានកូនប៉ុន្មាននាក់មីង?

ជឿន ៖ ខ្ញុំកូន៥នាក់ ។

ប៊ុនថន ៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ជឿន ៖ ប្រុស៤ស្រីតែមួយ ។

ប៊ុនថន ៖ ប្រុស៤ស្រីមួយ?

ជឿន ៖ ចាស ។

ប៊ុនថន ៖ និយាយថាកូនពៅក្រោយគេអាយុប៉ុន្មានហើយមីង?

ជឿន ៖ កូនស្រីអាយុ១៧ឆ្នាំ ។

ប៊ុនថន ៖ ធំដែលហើយ ។

ជឿន ៖ ធំហើយ ។

ប៊ុនថន ៖ មានបានទៅរៀនទេមីង?

ជឿន ៖ ឲ្យទៅរៀនវាឈប់រៀនឡើងពីរឆ្នាំ អាបង១ខឹងវាអត់ទៅរៀន ។

ប៊ុនថន ៖ ចឹងឈប់រៀនធ្វើអីដែលមីង?

ជឿន ៖ មានធ្វើអីនៅផ្ទះជួយម៉ែប៉ុណ្ណឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ អត់មានបានធ្វើអីផង ។

ប៊ុនថន ៖ តែកូនបង១បានរៀនយ៉ាងម៉េចដែរ?

ជឿន ៖ កូនបង១អាបងគេបង្អស់រៀនបានថ្នាក់ទី៣សម័យខ្មែរក្រហមហ្នឹង ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ កាលនោះថ្នាក់ទី៣បើក្មេងឥឡូវស្មើថ្នាក់ទី៨ក្មេងឥឡូវហ្នឹងថ្នាក់ទី៣ពីមុននោះ ។

ប៊ុនថន ៖ បាទ ។

ជឿន ៖ ចាស!រៀនបានជ្រៅជ្រះដាងហើយក្រោយមករៀនបានថ្នាក់ទី៧ទី៦ប៉ុណ្ណឹង ។

ប៊ុនថន ៖ បាទ!ហើយរាល់ថ្ងៃមីងធ្វើការដែលឬក៏នៅផ្ទះ?

ជឿន ៖ នៅផ្ទះ ។

ប៊ុនថន ៖ អត់មានធ្វើការខាងឃុំភូមិអីទេ?

ជឿន ៖ ខ្ញុំជំនួយការភូមិ ។

ប៊ុនថន ៖ អូស!បានភូមិដែរ?

ជឿន ៖ ចាស ។

ប៊ុនថន ៖ គ្រួសារអ្នកមីងធ្វើប៉ូលីសទៅ?

ជឿន ៖ ចាស ។

ប៊ុនថន ៖ គាត់មកសម្រាក់ផ្ទះឬគាត់នៅហ្នឹងតែម្តង?

ជឿន ៖ នៅហ្នឹងនៅបន្ទាយប៉ុស្តិគេហ្នឹង ។

ប៊ុនថន :	បាទ!ចឹងជិតដែលពីហ្នឹងទៅ?
ជឿន :	៩៣ ភូមិ៩៣ ។
ប៊ុនថន :	៥ទៅ៦ប៉ុន្មានគីឡូ?
ជឿន :	ខ្ញុំមិនដឹងប៉ុន្មានទេ អត់ដឹងកណត់បាន ។
ប៊ុនថន :	ពីរបីថ្ងៃគាត់មកម្ដង?
ជឿន :	ចាស ។
ប៊ុនថន :	ចឹងខ្ញុំរំខានមីងច្រើនហើយ ។
ជឿន :	ចាស!អត់អីទេ ។
ប៊ុនថន :	ចឹងខ្ញុំអត់មានអីសួរអ្នកមីងទៀតហើយ ។
ជឿន :	ចាស ។
ប៊ុនថន :	ចឹងអរគុណអ្នកមីង ។
ជឿន :	ចាស ។

**ចប់**